# ការបកស្រាយអំពីប្រព័ន្ធទ្រព្យសម្បត្តិរួមប្តីប្រពន្ធ

Professor of Law, Waseda University

Masayuki Tanamura

## 1 សេចក្តីផ្តើម

<u>និយមន័យនៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ</u>

នៅពេលដែលរៀបអាពាហ៍ពិពាហ៍ តើនឹងធ្វើឲ្យជះឥទ្ធិពលបែបណាដល់ទំនាក់ទំនងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ?

ពោលគឺ តើទ្រព្យសម្បត្តិដែលប្តី ឬ ប្រពន្ធទទួលបាន និងទ្រព្យសម្បត្តិដែលប្តីប្រពន្ធទទួលបានដោយការសហការគ្នានឹងត្រូវបង្វែរបែបណា (កម្មសិទ្ធិលើទ្រព្យសម្បត្តិប្តីប្រពន្ធ)? តើអ្នកណាអាចប្រើប្រាស់និងគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធបានហើយប្រើប្រាស់ និង គ្រប់គ្រងដោយរបៀបណា (ការប្រើប្រាស់ និង គ្រប់គ្រងលើទ្រព្យសម្បត្តិប្តីប្រពន្ធ)? តើអ្នកណាត្រូវទទួលបន្ទុកសោហ៊ុយដើម្បីជួយផ្គត់ផ្គង់ជីវភាពរួមគ្នារបស់ប្តីប្រពន្ធ (ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍)? តើប្តី ឬ ប្រពន្ធម្ខាងទៀតចាំបាច់ត្រូវតែបង់ចំពោះកាតព្វកិច្ចដែលប្តីប្រពន្ធណាម្ខាងមានបន្ទុកដែរឬទេ (បន្ទុកនៃកាតព្វកិច្ច)? ក្នុងករណីដែលអចលនវត្ថុដើម្បីអាស្រ័យនៅរបស់ប្តីប្រពន្ធត្រូវបានចាត់ចែង តើការអាស្រ័យនៅរបស់ប្តី ឬ ប្រពន្ធម្ខាងទៀតនឹងត្រូវបានការពារដោយបែបណា (សិទ្ធិអាស្រ័យនៅរបស់ប្តីប្រពន្ធ)?

ស្តីអំពី ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ ជាមូលដ្ឋានរួមមាន ៖ ប្រព័ន្ធទ្រព្យដោយឡែក (Separate Property System) គឺជាប្រព័ន្ធដែលមិនធ្វើឲ្យមានផលប៉ះពាល់ដល់ទំនាក់ទំនងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធទេ ទោះបីជាបានរៀបអាពាហ៍ពិពាហ៍ក៏ដោយ និង ប្រព័ន្ធទ្រព្យរួម (Community Property System) គឺជាប្រព័ន្ធដែលនឹងមានផលប៉ះពាល់ទៅដល់ទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធនៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ ហើយទ្រព្យទាំងនោះត្រូវក្លាយជាទ្រព្យរួម។

នៅក្នុងប្រព័ន្ធទ្រព្យដោយឡែក ជាគោលការណ៍ ប្តីប្រពន្ធមានកម្មសិទ្ធិ និង ការគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួន។ នៅប្រទេសអង់គ្លេស និង រដ្ឋភាគច្រើននៅសហរដ្ឋអាមេរិកប្រើប្រាស់ប្រព័ន្ធនេះ។ ហើយនៅប្រទេសជប៉ុនក៏ប្រើប្រព័ន្ធទ្រព្យដោយឡែកនេះដែរ។

គេបាននិយាយថា ប្រព័ន្ធទ្រព្យដោយឡែកបានធានានូវភាពឯករាជ្យនៃទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ហើយធ្វើឲ្យទំនាក់ទំនងគតិយុត្តនៃទ្រព្យមានភាពច្បាស់លាស់ ហើយធ្វើឲ្យមានសុវត្ថិភាពលើកិច្ចការជំនួញ។ ផ្ទុយមកវិញក៏មានការរិះគន់ដែរថា ប្រព័ន្ធនេះមិនអាចឆ្លុះបញ្ចាំងឲ្យឃើញនូវទំនាក់ទំនងនៃការសហការគ្នាខាងផ្នែកសេដ្ឋកិច្ចរបស់ប្តី

ប្រពន្ធ និង ភាពតែមួយនៃផ្នែកសេដ្ឋកិច្ចរបស់ប្ដីប្រពន្ធខ្លាំងពេក ហើយមិនអាចវាយតម្លៃបានអំពីការងារដែលប្រពន្ធត្រូវជួយគាំទ្រទៅប្ដី។

ប្រព័ន្ធទ្រព្យសម្បត្តិរួមគឺ ជាប្រព័ន្ធដែលទទួលស្គាល់អំពីអត្ថិភាពនៃទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ តាមរយៈអាពាហ៍ពិពាហ៍ក្នុងទំហំមួយដែលបានកំណត់ ហើយនៅពេលដែលអាពាហ៍ពាហ៍រលាយ នឹងត្រូវយកទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធមកធ្វើការបែងចែក។ ប្រព័ន្ធនេះគេបានយកមកប្រើនៅក្នុងប្រទេសបារាំង និង ប្រទេសនានាដែលបានទទួលឥទ្ធិពលនៃប្រពន្ធនេះ។ ភាគច្រើនប្រទេសទាំងនេះ ប្រើប្រព័ន្ធដែលយកប្រាក់ចំណូលប្ដីប្រពន្ធរកបានធ្វើជាទ្រព្យសម្បត្តិរួម។ បើទ្រព្យសម្បត្តិដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ និង ទ្រព្យសម្បត្តិដែលទទួលបាននៅក្នុងអំឡុងពេលនៃអាពាហ៍ពិពាហ៍ដោយពុំមានតម្លៃតប ចាត់ទុកថា គឺជាទ្រព្យសម្បត្តិដោយឡែក។ ករណីភាគច្រើនទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិដែលទទួលបានក្នុងទំហំនៃអំឡុងពេលអាពាហ៍ពិពាហ៍។

ផ្ទុយមកវិញចំពោះប្រព័ន្ធទ្រព្យរួម គឺជាប្រព័ន្ធដែលធ្វើឲ្យអាចសម្រេចនូវការវាយតម្លៃអំពីភាពស្មើភាពគ្នា និងភាពតែមួយនៃផ្នែកសេដ្ឋកិច្ចរបស់ប្ដីប្រពន្ធបាន ប៉ុន្តែ គុណវិបត្តិនៃប្រព័ន្ធនេះគឺ ធ្វើឲ្យទំនាក់ទំនងគតិយុត្តមានភាពស្មុគស្មាញ ហើយធ្វើឲ្យប៉ះពាល់ដល់ទំនាក់ទំនងជាមួយតតិយជននិងសុវត្ថិភាពនៃកិច្ចការជំនួញ។

ដូច្នេះហើយ ទោះបីជាចាប់ផ្ដើមពីប្រព័ន្ធមួយណាក៏ដោយ ក៏ប្រព័ន្ធទាំង២នេះ នៅតែមានផលវិបាកម៉្យាងម្នាក់ដែរ។

ម្យ៉ាងវិញទៀតក៏មាន "ប្រព័ន្ធដែលយកទ្រព្យសម្បត្តិដែលនៅសល់ធ្វើជាទ្រព្យរួម" នៅប្រទេសអាឡឺម៉ង់ ("ប្រព័ន្ធដែលយកប្រយោជន៍ដែលទទួលបានបន្ថែមមកធ្វើជាទ្រព្យរួម") បានយកប្រព័ន្ធទ្រព្យសម្បត្តិដោយឡែកមកធ្វើជាមូលដ្ឋាន ហើយនៅពេលដែលអាពាហ៍ពិពាហ៍នោះរលាយ ប្រព័ន្ធនេះនឹងធ្វើការជម្រះបញ្ជីនូវទ្រព្យសម្បត្តិដែលប្ដីប្រពន្ធទទួលបាននៅអំឡុងពេលអាពាហ៍ពិពាហ៍។ ហើយក៏មាន "ប្រព័ន្ធដែលយកទ្រព្យសម្បត្តិដែលទទួលបាននៅក្រោយអាពាហ៍ពិពាហ៍ធ្វើជាទ្រព្យរួម" នៅប្រទេសបារាំងដែលជាប្រភេទនៃប្រព័ន្ធនឹងការធ្វើការជម្រះបញ្ជីនៅក្នុងនីតិវិធីនៃការជម្រះបញ្ជីនៅពេលដែលអាពាហ៍ពិពាហ៍បានរលាយផងដែរ។

នៅប្រទេសកម្ពុជាក៏បានទទួលឥទ្ធិពលពីក្រមរដ្ឋប្បវេណីប្រទេសបារាំងនៅក្នុងសម័យអាណានិគម ហើយនៅក្នុងច្បាប់ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសារឆ្នាំ 1989 ក៏បានប្រើប្រាស់ប្រព័ន្ធទ្រព្យសម្បត្តិរួមប្ដីប្រពន្ធដែរ។ ដូច្នេះហើយនៅពេលដែលធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជា គេក៏បានគោរពតាមលំនាំបែបនេះ ហើយក៏ធ្វើការពិចារណាទៅលើការអភិវឌ្ឍន៍សេដ្ឋកិច្ច និង ស្ថានភាពនៃការប្រែប្រួលជាច្រើនទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធនៅក្នុងកម្ពុជា ព្រមទាំងបានព្យាករណ៍នូវបញ្ហាស្មុគស្មាញដែលនឹងកើតមាន ហើយថែមទាំងមើលទៅលើទំនោរនៅបណ្ដាលប្រទេសមួយចំនួនផងដែរ។ ដូច្នេះនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ក៏បានបញ្ញត្តអំពីប្រព័ន្ធទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធផងដែរ។

ហេតុដូច្នេះហើយ សិក្ខាសាលានេះនឹងធ្វើការបកស្រាយអំពីប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធនៅប្រទេសកម្ពុជា ដោយយោងទៅលើការពិភាក្សាដែលបានធ្វើឡើងនៅពេលបង្កើតសេចក្ដីព្រាងក្រមរដ្ឋប្បវេណី ស្ថានភាពជាក់ស្ដែងរបស់យុត្តិសាស្ត្រតុលាការ និង វិវាទនៅក្រោយពេលនោះ ព្រមទាំងទំនោរនៅបរទេស ហើយជាពិសេស គឺយុត្តិសាស្ត្ររបស់តុលាការនៅប្រទេសជប៉ុនជាដើម។

## 2 ប្រព័ន្ធទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

### កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា គន្ថីទី7 ជំពូកទី3 ផ្នែកទី3 កថាភាគទី1 ដែលបញ្ញត្តអំពីប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យាបានទទួលស្គាល់នូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

ពោលគឺ ①ប្តីប្រពន្ធអាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬ ក្រោយអាពាហ៍ពិពាហ៍បាន។ ប៉ុន្តែកិច្ចសន្យានេះមិនអាចធ្វើផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកាតព្វកិច្ចនិងភាគបម្រុងបានឡើយ។ ②នៅពេលដែលមិនបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធទេនឹងត្រូវអនុលោមតាមប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ (CCកម្ពុជា មាត្រា969)។

ក្រមរដ្ឋប្បវេណីនេះបានទទួលស្គាល់នូវសេរីភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធក៏ពិតមែន ប៉ុន្តែ បានកម្រិតនូវអានុភាពនៃកិច្ចសន្យាដែលមានខ្លឹមសារបោះបង់នូវអាហារកាតព្វកិច្ចរវាងប្តីប្រពន្ធ ឬ សិទ្ធិលើទ្រព្យសម្បត្តិដែលជាសិទ្ធិសំខាន់ចំពោះប្តីប្រពន្ធ។

### ភាពចាំបាច់នៃទម្រង់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និង លក្ខខណ្ឌតតាំង

①កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវធ្វើជាលាយលក្ខណ៍អក្សរ។ ②ក្នុងករណីដែលប្តីប្រពន្ធបានធ្វើកិច្ចសន្យាផ្សេងពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ បើមិនបានចុះបញ្ជីទេ មិនអាចយកកិច្ចសន្យានោះមកតតាំងជាមួយនឹងតតិយជនបានឡើយ (CCកម្ពុជា មាត្រា970)។

នៅក្នុងកថាខណ្ឌទី១ ច្បាប់បានទាមទារនូវភាពចាំបាច់នៃទម្រង់កិច្ចសន្យាដែលត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយនៅក្នុងកថាខណ្ឌទី២ បានទាមទារនូវការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលជាលក្ខខណ្ឌតតាំងនៅពេលដែលកិច្ចសន្យានោះផ្សេងពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់។

### ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់

ប្រសិនបើនៅក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធមិនបានកែសម្រួលអ្វីពិសេសទេ ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់នឹងត្រូវយកមកអនុវត្ត (CCកម្ពុជា មាត្រា969 កថា.ទី2)។

### ចំណែកបន្ទុកនៃសោហ៊ុយអាពាហ៍ពិពាហ៍

ប្តីប្រពន្ធ ត្រូវមានចំណែកបន្ទុកលើសោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍ ដោយពិចារណាទៅលើ ទ្រព្យសម្បត្តិ ប្រាក់ចំណូល និង ស្ថានភាពផ្សេងៗទៀត (CCកម្ពុជា មាត្រា971)។

ចំពោះសោហ៊ុយដែលចាំបាច់ដើម្បីថែរក្សាជីវភាពរស់នៅ ក្នុងមាត្រានេះបានចែងថា គឺជាចំណែកដែលត្រូវទទួលបន្ទុក ដោយយោងទៅតាមទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធទាំងសងខាង ប្រាក់ចំណូល ឋានៈនៅក្នុងសង្គម និង មុខរបរជាអាទិ៍។

## កម្មសិទ្ធិលើទ្រព្យសម្បត្តិរួមប្តីប្រពន្ធ

ទ្រព្យសម្បត្តិរួមប្តីប្រពន្ធបែងចែកចេញជាទ្រព្យសម្បត្តិដោយឡែក (ទ្រព្យសម្បត្តិផ្ទាល់ខ្លួន) និង ទ្រព្យសម្បត្តិរួម (ទ្រព្យសម្បត្តិដែលបានបញ្ចូលគ្នា)។

### ទ្រព្យសម្បត្តិដោយឡែក

ជាទ្រព្យសម្បត្តិដោយឡែកដែលស្ថិតក្រោមកម្មសិទ្ធិរបស់សហព័ទ្ធតែម្ខាងដូចជា (1) ទ្រព្យសម្បត្តិដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ (2) ទ្រព្យសម្បត្តិដែលទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ( 3 ) ទ្រព្យសម្បត្តិជាតម្លៃតបដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិត្រង់ចំណុច (1) ឬ (2) (CCកម្ពុជា មាត្រា972)។

### ទ្រព្យសម្បត្តិរួម

ជាទ្រព្យសម្បត្តិដែលមានរួមគ្នា ហើយសំដៅទៅលើទ្រព្យសម្បត្តិទាំងឡាយណាដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ក្រៅពីទ្រព្យសម្បត្តិដោយឡែក (CCកម្ពុជា មាត្រា973)។

មាត្រានេះបានកំណត់ថា ទ្រព្យសម្បត្តិដែលទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ក្រៅពីទ្រព្យសម្បត្តិដោយឡែក នឹងត្រូវក្លាយជាទ្រព្យសម្បត្តិរួម។ នៅប្រទេសកម្ពុជាកំពុងប្រើប្រាស់នូវប្រព័ន្ធទ្រព្យសម្បត្តិរួមប្តីប្រពន្ធដូចដែលបានលើកឡើងនៅខាងលើ។

## ការគ្រប់គ្រងនិងការប្រើប្រាស់ទ្រព្យសម្បត្តិ

①ប្តីប្រពន្ធមានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរួម។ ហើយក្រមរដ្ឋប្បវេណីក៏បានចែងអំពីសិទ្ធិប្រើប្រាស់ទទួលផលប្រយោជន៍ និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនរៀងៗខ្លួនដែរ (CCកម្ពុជា មាត្រា974 កថា.ទី១) ។ ②ក្រមនេះក៏បានចែងអំពី សិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរួម ដោយផ្អែកលើភាពចាំបាច់នៅក្នុងជីវភាព (មាត្រាដដែល កថា.ទី២)។ ហើយ③ បានទទួលស្គាល់នូវសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរួម និងមានសិទ្ធិទាមទារនូវចំណាត់ការដើម្បីគ្រប់គ្រង និង រក្សាទុកនូវទ្រព្យសម្បត្តិរួម (មាត្រាដដែល កថា.ទី3)។ ម្យ៉ាងទៀត ④ប្តីប្រពន្ធអាចទាមទារនូវការសម្រេចសេចក្តីទាក់ទងទៅនឹងការគ្រប់គ្រង និង ប្រើប្រាស់នៅក្នុងករណីដែលមិនអាចពិភាក្សាគ្នាបានអំពីការគ្រប់គ្រង និង ប្រើប្រាស់លើទ្រព្យសម្បត្តិរួម (មាត្រាដដែល កថា.ទី៤) ។

ក្រៅពីកម្មសិទ្ធិអវិភាគនៃគន្លឹស្តីអំពី "សិទ្ធិប្រត្យក្ស" និង បទបញ្ញត្តិពិសេស នៅចំណុច ③ បានកំណត់ថា ប្តីប្រពន្ធអាចទាមទារនូវការចុះបញ្ជីអំពីទ្រព្យសម្បត្តិរួមប្តីប្រពន្ធហើយនៅចំណុច ④បានកំណត់ថាប្តីប្រពន្ធអាចទាមទារឲ្យតុលាការធ្វើការចាត់ចែងដែលចាំបាច់ ឬ ចំណាត់ការ នៅពេលដែលមិនអាចនិយាយត្រូវគ្នា។

## ការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះកាតព្វកិច្ច

ប្តីប្រពន្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាពចំពោះ ①សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្តីប្រពន្ធ និងសោហ៊ុយដើម្បីការអប់រំឬការព្យាបាលថែទាំកូនជាអាទិ៍ ②កាតព្វកិច្ច និង ករណីយកិច្ចផ្សេងៗទៀត ដែលប្តីប្រពន្ធបានព្រមព្រៀងតាមលិខិតជាលាយលក្ខណ៍អក្សរនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ③សោហ៊ុយដើម្បីគ្រប់គ្រង និង រក្សាទ្រព្យសម្បសត្តិរួម (CCកម្ពុជា មាត្រា975) ។

## ការចាត់ចែងទ្រព្យសម្បត្តិរួម

①ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមិនអាចយកទៅលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតដោយមិនមានការយល់ព្រមពីប្តីប្រពន្ធទាំងសងខាងទេ (CCកម្ពុជា មាត្រា976 កថា.ទី១) ។ ②នៅពេលដែលមានស្ថានភាពមិនអាចជៀសវាងបានសម្រាប់ការថែទាំជីវភាពរួមក្នុងអាពាហ៍ពិពាហ៍ និង ដើម្បីជីវភាពរស់នៅនោះប្តី ឬ ប្រពន្ធណាម្ខាងអាចលក់ឬ ធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួមបាន ដោយទទួលការអនុញ្ញាតពីតុលាការ (មាត្រាដដែល កថា.ទី2) ។ ③ក្នុងករណីដែលប្តី ឬ ប្រពន្ធណាម្ខាងបានលក់ ឬ ធ្វើការចាត់ចែងផ្សេងទៀតនូវទ្រព្យសម្បត្តិរួមដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតផង និង គ្មានការអនុញ្ញាតពីតុលាការផង សហព័ទ្ធដែលមិនបានផ្តល់ការយល់ព្រមអាចទាមទារឲ្យលុបចោលនូវការចាត់ចែងនោះទៅតុលាការបាននៅក្នុងអំឡុងពេល២(ពីរ)ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះជាអចលនវត្ថុនៃការអាស្រ័យនៅ និង នៅក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះជាទ្រព្យសម្បត្តិផ្សេង (មាត្រាដដែល កថា.ទី៣)។

## ការអាស្រ័យនៅទ្រព្យសម្បត្តិដោយឡែក

①ប្តីប្រពន្ធម្ខាងអាចអាស្រ័យនៅអចលនវត្ថុដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ហើយដែលត្រូវបានប្រើសម្រាប់ការអាស្រ័យនៅរបស់គ្រួសារបាន។ ②ទោះបីជាសហព័ទ្ធម្ខាងទៀតបានចាត់ចែងអចលនវត្ថុនោះក៏ដោយ ក៏អាចបន្តអាស្រ័យនៅអចលនវត្ថុនោះបានដែរ (CCកម្ពុជា មាត្រា977) ។

ការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ

①ក្នុងករណីដែលប្តីប្រពន្ធលែងលះគ្នា ត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង។ ②នៅពេលដែលមិនអាចពិភាក្សាគ្នារវាងប្តីប្រពន្ធទេ សហព័ទ្ធនីមួយៗ ត្រូវទទួលបាននូវទ្រព្យសម្បត្តិដោយឡែក។ សហព័ទ្ធនីមួយៗ មានសិទ្ធិទទួលយក១ភាគ២នៃទ្រព្យសម្បត្តិរួម។ ប៉ុន្តែ បើមានករណីពិសេស និង មានការទាមទាររបស់ប្តីប្រពន្ធណាម្ខាង ការបែងចែងទ្រព្យសម្បត្តិរួម អាចធ្វើឡើងដោយធ្វើការពិចារណាលើទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗអំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្ត និង ផ្លូវកាយ និងផលប្រយោជន៍របស់កូនជាអាទិ៍។ ③គេហកិច្ចត្រូវចាត់ទុកថា មានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះដែរ (CCកម្ពុជា មាត្រា980)។

## 3 ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ និង ការចុះបញ្ជីអចលនវត្ថុ

ប្រព័ន្ធនៃការចុះបញ្ជីអចលនវត្ថុនៅប្រទេសកម្ពុជា

ប្រព័ន្ធនៃប្រទេសកម្ពុជាមានភាពខុសគ្នាទៅនឹងច្បាប់នៅប្រទេសជប៉ុនយ៉ាងខ្លាំង ត្រង់ចំណុចស្តីអំពី ①កម្មវត្ថុនៃការចុះបញ្ជី ②អានុភាពនៃការចុះបញ្ជី ③ឯកសារបញ្ជាក់អំពីមូលហេតុនៃការចុះបញ្ជី ④សមត្ថកិច្ចនៃការចុះបញ្ជី។

ជាដំបូង ស្តីអំពីចំណុច ①កម្មវត្ថុនៃការចុះបញ្ជី។ នៅប្រទេសកម្ពុជាដី និង អាគារមិនមែនជាវត្ថុផ្សេងៗពីគ្នាឡើយ ហើយគេបានចុះបញ្ជីកម្មសិទ្ធិនៃអាគារលើដីនោះជាអចលនវត្ថុតែមួយ។ ម្យ៉ាងទៀត ②ស្តីពីអានុភាពនៃការចុះបញ្ជីវិញទាក់ទងនឹងការបង្កើត ឬ ការផ្ទេរនូវផលុបភោគ និង សិទ្ធិប្រាតិភោគប្រត្យក្ស "ការចុះបញ្ជី" ជាលក្ខខណ្ឌតតាំង ប៉ុន្តែ ការផ្ទេរនូវកម្មសិទ្ធិនៃអចលនវត្ថុដោយការព្រមព្រៀងវិញ "ការចុះបញ្ជី" នឹងក្លាយទៅជាលក្ខខណ្ឌដើម្បីបង្កើតអានុភាព ហើយប្រសិនបើមិនបានចុះបញ្ជីទេ អានុភាពនៃការផ្ទេរកម្មសិទ្ធិក៏នឹងមិនកើតឡើងដែរ (CCកម្ពុជា មាត្រា 133～135)។ ហើយស្តីអំពី ③ឯកសារបញ្ជាក់អំពីមូលហេតុនៃការចុះបញ្ជីវិញ ទាក់ទងទៅនឹងលិខិតកិច្ចសន្យាលក់ទិញអចលនវត្ថុជាអាទិ៍ បើមិនបានធ្វើឡើងដោយលិខិតយថាភូតទេ អានុភាពនឹងមិនកើតមានទេ (ច្បាប់ដដែល មាត្រា336 កថា.ទី2) ហើយការបង្កើតកិច្ចសន្យាផ្សេងក្រៅពីនោះ ដូចជាកិច្ចសន្យាបង្កើតហ៊ីប៉ូតែកជាអាទិ៍ ក៏អាចធ្វើឡើងជាលិខិតលាយលក្ខណ៍អក្សរដែលធ្វើឡើងដោយមន្ត្រីមានសមត្ថកិច្ចក៏បានដែរ។ រីឯ④ការដាក់ពាក្យសុំចុះបញ្ជី និង សមត្ថកិច្ចអនុវត្តការចុះបញ្ជីនៅប្រទេសជប៉ុន គឺជាមន្ទីរកិច្ចការច្បាប់ (Regional Legal Affairs Bureau) ប៉ុន្តែនៅប្រទេសកម្ពុជារដ្ឋបាលសុរិយោដីមានដូចជា ក្រសួងដែនដីរាជធានី និង ខេត្ត ហើយ រដ្ឋបាលសុរិយោដីដែលទទួលពាក្យសុំត្រូវបានបែងចែកទៅតាមថ្នាក់ក្រុង ស្រុក ខណ្ឌ ឬ រាជធានី ខេត្ត។

នៅប្រទេសកម្ពុជា សៀវភៅគោលបញ្ជីដីធ្លីត្រូវបានបំផ្លិចបំផ្លាញដោយរដ្ឋាភិបាលប៉ុលពត និង ក្រោមភាពច្របូកច្របល់នៃសង្គ្រាមផ្ទៃក្នុងក្រោយពេលនោះ។ ច្បាប់ភូមិបាលឆ្នាំ 1992 និង 2001 បានចែងនូវបញ្ញត្តិថា មិនទទួលស្គាល់នូវកម្មសិទ្ធិលើអចលនវត្ថុនៅមុនឆ្នាំ1979ទេ ហើយកម្ពុជាបានចាប់ផ្តើមបង្កើតនូវសៀវភៅគោលបញ្ជីដីធ្លីចាប់ពីចំណុចសូន្យបន្តរហូតរៀងមក។ ជាលទ្ធផល គិតត្រឹមចុងខែកញ្ញា ឆ្នាំ២០១៧ ក្នុងពេលបច្ចុប្បន្ននេះ មានតែដីចំនួន

ប្រហែល65%នៃផ្ទៃប្រទេសតែប៉ុណ្ណោះដែលបានធ្វើការចុះបញ្ជីដំបូង (ចុះបញ្ជីស្តីពីអត្ថិភាពនៃកម្មសិទ្ធិ)។ ប៉ុន្តែ ដោយសារតែសិទ្ធិកាន់កាប់ពិសេស (មានភាពស្រដៀងគ្នាទៅនឹងកម្មសិទ្ធិលើដីធ្លីដែរ) ត្រូវបានទទួលស្គាល់ដោយច្បាប់ភូមិបាលឆ្នាំ២០០១ (CCកម្ពុជា មាត្រា242 និង មាត្រា243) ដូច្នេះហើយ ទំនាក់ទំនងនៃសិទ្ធិលើអចលនវត្ថុ និង ការផ្សព្វផ្សាយជាសាធារណៈ (ការចុះបញ្ជី) មានភាពស្មុគស្មាញខ្លាំង។

<u>ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ</u>

បន្ថែមពីនេះ នៅប្រទេសកម្ពុជាបានយកប្រព័ន្ធទ្រព្យសម្បត្តិរួមប្តីប្រពន្ធ មកធ្វើជាប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ហើយបានទទួលស្គាល់នូវការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ថាជាប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា។ ប៉ុន្តែ កិច្ចសន្យា នេះមិនត្រឹមតែធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់ទំនាក់ទំនងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធតែប៉ុណ្ណោះទេ ថែមទាំងមិនអាចយកមកតតាំងបានឡើយ (CCកម្ពុជា មាត្រា970) បើកិច្ចសន្យានោះមិនបានចុះបញ្ជីក្នុងករណីដែលជួយការពារដល់តតិយជនដែលធ្វើកិច្ចការជំនួញជាមួយនឹងប្តីប្រពន្ធនោះ។

ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធឆ្នាំ2013 បានយកនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ ធ្វើជាស្ថាប័នមានសមត្ថកិច្ចក្នុងកិច្ចការចុះបញ្ជី ហើយបានចែងអំពីចុះបញ្ជីការផ្លាស់ប្តូរការលុបចោលការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និង នីតិវិធីនៃការការចេញលិខិតបញ្ជាក់ជាដើម។ ប៉ុន្តែ អ្នកដែលមិនបានដឹងអំពីអត្ថិភាពនៃក្រុមចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធក៏មានច្រើនផងដែរ ដូច្នេះហើយ ស្ទើរតែគ្មានអ្នកប្រើប្រាស់នូវការចុះបញ្ជីនេះទេ។

## 4 វិវាទទាក់ទងនៅនឹងទ្រព្យសម្បត្តិរួមប្តីប្រពន្ធ

<u>①ក្នុងករណីដែលប្តីប្រពន្ធកំពុងរស់នៅបែកគ្នា ហើយមានអ្នកណាម្នាក់បានទាមទារឲ្យបែងចែកអចលនវត្ថុដែលជាទ្រព្យសម្បត្តិរួមនៃការអាស្រ័យនៅ តើនឹងត្រូវក្លាយជាយ៉ាងណា?</u>

ក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជាបានទទួលស្គាល់នូវទ្រព្យសម្បត្តិដែលប្តីប្រពន្ធទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ថា ជាគោលការណ៍នឹងត្រូវក្លាយជាទ្រព្យសម្បត្តិរួម (CCកម្ពុជា មាត្រា973) ហើយប្តីប្រពន្ធមានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិនោះក្នុងទំហំនៃភាពចាំបាច់ (ច្បាប់ដដែល មាត្រា974 កថា.ទី2)ម្យ៉ាងទៀត ក៏មានសិទ្ធិទាមទារឲ្យធ្វើចំណាត់ការដែលចាំបាច់ដើម្បីគ្រប់គ្រង និង រក្សាទុកទ្រព្យសម្បត្តិរួមបានផងដែរ (ច្បាប់ដដែលមាត្រាដដែល កថា.ទី3)។ បន្ថែមពីនេះទៀត នៅក្នុងការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ ប្តីប្រពន្ធក៏មានសិទ្ធិទាមទារឲ្យបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ ដោយធ្វើការពិចារណាលើស្ថានភាពដូចជា ទំហំនៃការបរិច្ចាករបស់ភាគីនីមួយៗ អាយុ ទ្រព្យសម្បត្តិ និង ប្រាក់ចំណូល ស្ថានភាពផ្លូវចិត្ត និង ផ្លូវកាយជាអាទិ៍ (ច្បាប់ដដែល មាត្រា 980) ។

ប៉ុន្តែផ្ទុយមកវិញ ក្រមរដ្ឋប្បវេណីបានចែងថា ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ អាចទាមទារឲ្យបែងចែកវត្ថុកម្មសិទ្ធិអវិភាគបានគ្រប់ពេលវេលា (ច្បាប់ដដែល មាត្រា211 កថា.ទី1) ហើយនៅពេលដែលការពិភាក្សារវាងម្ចាស់

កម្មសិទ្ធិអវិភាគ មិនអាចសម្របសម្រួលគ្នាបានទេនោះ អាចទាមទារទៅតុលាការឲ្យធ្វើការបែងចែកវត្ថុជាក់ស្តែងនោះ ឬ ដោយការបែងចែកប្រាក់ទៅតាមចំនួននៃចំណែក (ច្បាប់ដដែល មាត្រា212) ។

នៅប្រទេសជប៉ុន សិទ្ធិទាមទារឲ្យបែងចែកចំណែកកម្មសិទ្ធិអវិភាគដែលបានបញ្ញត្តនៅក្នុងក្រមរដ្ឋប្បវេណីគឺ ជាសិទ្ធិលើទ្រព្យសម្បត្តិដែលសាកសមនឹងគិតថាជាលក្ខណៈចម្បងនៃកម្មសិទ្ធិអវិភាគ ក្នុងការគ្រប់គ្រងជាក់ស្តែងលើកម្មវត្ថុទាំងស្រុងដោយសេរី ប៉ុន្តែ នៅក្នុងសំណុំរឿងដែលប្តីបានទាមទារឲ្យបែងចែកចំណែកកម្មសិទ្ធិអវិភាគនៃអចលនវត្ថុដែលប្រពន្ធ និង កូនអាស្រ័យបាននៅ តុលាការបានធ្វើការសម្រេចសេចក្តីថា មិនទទួលស្គាល់សិទ្ធិទាមទារឲ្យបែងចែកចំណែកកម្មសិទ្ធិអវិភាគនោះទេ ក្នុងករណីដែលមើលឃើលថា វាមានភាពមិនត្រឹមត្រូវខ្លាំងពេកទាក់ទងទៅនឹងគោលបំណង និង លក្ខណៈនៃទំនាក់ទំនងកម្មសិទ្ធិអវិភាគជាអាទិ៍ ហើយការអនុវត្តសិទ្ធិទាមទារឲ្យបែងចែកនោះ បានធ្វើឡើងក្រោយរូបភាពនៃការប្រើប្រាស់សិទ្ធិដោយបំពាន (សាលដីកាសាលាឧទ្ធរណ៍ប្រទេសជប៉ុន៖ 大阪高判 2005（平成１７）・６・９判時 1938 号８０頁)។

នៅក្នុងសាលដីកាខាងលើនេះបានសម្រេចថា មិនអនុញ្ញាតចំពោះ ការទទួលស្គាល់នូវសិទ្ធិទាមទារឲ្យបែងចែកចំណែកនៃវត្ថុកម្មសិទ្ធិអវិភាគដែលបានធ្វើឡើងនៅក្នុងសាលក្រមដើមនោះទេ ដោយសារតែការទាមទារនោះ គឺជាការប្រើប្រាស់សិទ្ធិដោយបំពាន។ ការសម្រេចបែបនេះ បានធ្វើឡើងដោយពិចារណាថា បើធ្វើការបែងចែកដែលតាមនីតិវិធីនៃការបែងចែកចំណែកអវិភាគនៃគន្លីស្តីពី "សិទ្ធិប្រត្យក្ស" នឹងធ្វើឲ្យប្រពន្ធបាត់បង់នូវលទ្ធភាពក្នុងការធ្វើលទ្ធកម្មតែម្នាក់ឯង ហើយ ម្យ៉ាងវិញទៀត ប្តីប្រពន្ធក៏មានករណីកិច្ចរួមរស់នឹងគ្នា សហការ និង សង្គ្រោះគ្នាទៅវិញទៅមកដែរ ដូច្នេះ តាមរយៈហេតុផលទាំងនេះ ប្រពន្ធមានករណីយកិច្ចការពារនូវការអាស្រ័យនៅរបស់ប្រពន្ធ និង កូន ហើយព្រមទាំងបានធ្វើការពិចារណាអំពីស្ថានភាពផ្លូវចិត្ត និង ផ្លូវកាយ និងផ្នែកសេដ្ឋកិច្ចរបស់ប្តីប្រពន្ធដែរ។ ហើយការដែលតុលាការបានធ្វើការពិចារណាបែបនេះ គឺផ្អែកទៅការបែងចែកដែលនឹងត្រូវធ្វើឡើងនៅនីតិវិធីនៃការបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធនៅពេលលែងលះគ្នានាពេលអនាគត និង ផ្អែកតាមទស្សនៈនៃការការពារនូវការអាស្រ័យនៅរបស់ប្រពន្ធ និង កូន។

ក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជាក៏មាននីតិវិធីនៃការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះគ្នាដែរ ដូច្នេះហើយ តុលាការគួរតែយកនីតិវិធីនៃការបែងចែកទ្រព្យសម្បត្តិនៅពេលដែលលែងលះគ្នាជាអាទិភាព ជាជាងធ្វើការបែងចែកដោយធ្វើតាមនីតិវិធីនៃការបែងចែកវត្ថុកម្មសិទ្ធិអវិភាគ។ ម្យ៉ាងទៀត នៅក្នុងមាត្រា៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាក៏មានបញ្ញត្តិស្តីពី ការហាមឃាត់មិនឲ្យប្រើប្រាស់សិទ្ធិដោយបំពានដែរ ដូច្នេះហើយ តុលាការគួរតែបកស្រាយដូចគ្នាទៅនឹងសាលដីកាខាងលើនេះក៏បានដែរ។

ជាការតបទៅនឹងសាលដីកាខាងលើនេះ ក៏មានសំណុំរឿងដែលតុលាការបានទទួលស្គាល់នូវការលក់ដេញថ្លៃដី និង អាគារ ហើយទទួលស្គាល់នូវការបែងចែកចំណែក១ ភាគ២ ពីប្រាក់នៃការលក់ដេញថ្លៃដែលបានដកសោហ៊ុយនៃការលក់ដេញថ្លៃនោះចេញដែរ នៅពលដែលពុំមានភាពចាំបាច់នៃការអាស្រ័យនៅ ហើយផ្អែកតាមទស្សនៈស្តីពីសុខមាលភាពរបស់កូននោះ ក៏ឃើញថា គ្មានភាពចាំបាច់ដើម្បីថែរក្សានូវអចលនវត្ថុនោះដែរ (សាលក្រមសាលាដំបូងប្រទេសជប៉ុន៖ 東京地判 2012（平成 24）・5・14LEX/DB【文献番号】25494441)។

ម្យ៉ាងទៀត ក៏មានសំណុំរឿងដែលមានការទាមទារឲ្យបែងចែកចំណែកអភិភាគដែលបានធ្វើឡើងពីភាគីខាងប្រពន្ធផងដែរ ហើយតុលាការបានទទួលស្គាល់នូវការទាមទារឲ្យបែងចែកចំណែកអភិភាគនោះ នៅពេលដែលប្រពន្ធមានទ្រព្យសម្បត្តិ និង ប្រាក់ចំណូលសមរម្យ ព្រមទាំងមិនមានភាពចាំបាច់ខ្លាំងនៃការអាស្រ័យនៅ។ (សាលក្រមសាលាដំបូងប្រទេសជប៉ុន៖ 東京地判 2015（平成 27）・6・3LEX/DB【文献番号】25530452)។

②ករណីដែលមានវិវាទអំពីប្រាក់បញ្ញើក្នុងធនាគារដែលជាទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ

មានសំណុំរឿងស្ដីពី ប្រាក់បញ្ញើនៅក្នុងធនាគារដែលបានដាក់តែឈ្មោះរបស់ប្ដី ហើយនៅពេលនោះមានការទាមទារពីប្ដីទៅកាន់ធនាគារថា សូមរំលាយកិច្ចសន្យានោះ ហើយ បង់ប្រាក់ទាំងនោះត្រឡប់មកវិញ។ ប៉ុន្តែ ក្នុងករណីនៃប្រាក់សន្សំធម្មតា និង មានកំណត់រយៈពេលបែបនេះ ធនាគារក៏បានបដិសេធនូវការទាមទារដែលប្ដីសុំឲ្យបង់ប្រាក់ត្រឡប់មកវិញតែម្នាក់ឯង ដោយសារតែប្រាក់បញ្ញើនោះ គឺទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ។ ស្ដីអំពីការកំណត់ និង ទទួលស្គាល់នូវអ្នកដាក់ប្រាក់បញ្ញើ គេបានទទួលស្គាល់ថា បុគ្គលដែលបានចូលរួមវិភាគទាននូវប្រាក់ គឺជាអ្នកដាក់ប្រាក់បញ្ញើ ដូច្នេះ តុលាការនៅប្រទេសជប៉ុន បានទទួលស្គាល់នូវការទាមទារឲ្យបង់ប្រាក់ដែលបានធ្វើឡើងភាគីខាងប្ដី ទោះបីជាលក្ខណៈដាក់ស្ដែង ប្រាក់នោះ គឺជាទ្រព្យសម្បត្តិរួមប្ដីប្រពន្ធក៏ដោយ (សាលក្រមសាលដំបូងប្រទេសជប៉ុន៖ 東京地判 2013・4・30 金判 1996 号 104 頁)។ នៅប្រទេសជប៉ុន គេបានបកស្រាយបែបនេះគឺ ដោយសារតែគេបានប្រើប្រាស់នូវប្រព័ន្ធទ្រព្យសម្បត្តិដោយឡែករបស់ប្ដីប្រពន្ធ ដែលមាននៅក្នុងមាត្រា 762 កថា.ទី1នៃក្រមរដ្ឋប្បវេណីប្រទេសជប៉ុន។ ម្យ៉ាងវិញទៀត ដោយសារតែគេបានទទួលស្គាល់ជាសត្យានុម័តនូវការបកស្រាយអំពីការកំណត់ និង ការទទួលស្គាល់នូវអ្នកដាក់ប្រាក់បញ្ញើ ដើម្បីការពារនូវសុវត្ថិភាពនៃកិច្ចការជំនួញ និងតតិយជន។

ប៉ុន្តែ នៅប្រទេសកម្ពុជា គេបានប្រើប្រាស់ប្រព័ន្ធទ្រព្យសម្បត្តិរួមប្ដីប្រពន្ធ ហើយស្ដីអំពីទ្រព្យសម្បត្តិរួម មាននូវចំណែករួមដែលមានសុក្ខានុពល ម្យ៉ាងទៀត ច្បាប់បានចែងថា ការលក់ទ្រព្យសម្បត្តិរួមក៏ដោយ ការចាត់ចែងជាអាទិ៍ក៏ដោយ ចាំបាច់ត្រូវមានការយល់ព្រមពីភាគីម្ខាងទៀត ហើយប្រសិនបើការចាត់ចែងនោះមិនបានទទួលការយល់ព្រមទេ ភាគីដែលមិនបានផ្ដល់ការយល់ព្រម អាចទាមទារឲ្យលុបចោលនូវការចាត់ចែងនោះបាន (CCកម្ពុជា មាត្រា 976)។ ដូច្នេះហើយ គេបានគិតថា ស្ថាប័នហិរញ្ញវត្ថុ ដូចជា ធនាគារជាអាទិ៍ មិនអាចបដិសេធនូវការទាមទាររបស់ប្ដីដែលសុំឲ្យបង់ប្រាក់ត្រឡប់មកវិញដោយមិនមានការយល់ព្រមពីប្រពន្ធបានឡើយ ទោះបីជាប្រាក់បញ្ញើបានដាក់តែឈ្មោះប្ដីក៏ដោយ លើកលែងតែការសងចំពោះអ្នកកាន់កាប់នូវសិទ្ធិលើបំណុល (ច្បាប់ដដែល មាត្រា439)មិនត្រូវបានរក្សាការពារ។

③ទ្រព្យសម្បត្តិរួម និង ការសងកាតព្វកិច្ចផ្ទាល់ខ្លួន

ឧទាហរណ៍ថា តើគេអាចអនុញ្ញាតឲ្យយកប្រាក់ចំណូលដែលប្ដីរកបាន យកមកសងកាតព្វកិច្ចដែលប្ដីត្រូវទទួលបន្ទុកនៅមុនពេលរៀបអាពាហ៍ពិពាហ៍ដែរឬទេ? ហើយ តើប្រពន្ធអាចលុបចោលនូវការសងកាតព្វកិច្ចដែលបានបង់

ឲ្យម្ចាស់បំណុលដែលធ្វើឡើងដោយមិនបានទទួលការយល់ព្រមពីខ្លួនឬទេ?

ប្រាក់ចំណូលរបស់ប្ដី នឹងត្រូវក្លាយជាទ្រព្យសម្បត្តិរួម ហើយប្ដីអាចយកទៅសងកាតព្វកិច្ចផ្ទាល់ខ្លួនតែម្នាក់ឯងបាន ដោយមិនចាំបាច់ទទួលបានការយល់ព្រមពីប្រពន្ធទេ ដោយសារតែច្បាប់មិនបានកម្រិតអំពីការចាត់ចែងចំពោះប្រាក់ទេ។

តាមរយៈនិយមន័យអំពីទ្រព្យសម្បត្តិរួមនៃមាត្រា973 ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានរាប់បញ្ចូលទាំងប្រាក់ចំណូលរបស់ប្ដី ជាទ្រព្យសម្បត្តិរួម។ ប៉ុន្តែ ដោយសារតែ (1) ចំពោះកម្មសិទ្ធិ និង ការកាន់កាប់លើ "ប្រាក់" ចាំបាច់ត្រូវតែមានភាពឯកភាពគ្នា ហើយ (2) នៅក្នុងច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារ មាត្រា ៣៧ ដែលជាមូលដ្ឋាននៃក្រមរដ្ឋប្បវេណីកម្ពុជាមាត្រា976 កថា.ទី1 ក៏បានលើកឡើងអំពី "ការលក់ដូរ ឬ ការធ្វើអំណោយនូវទ្រព្យសម្បត្តិរួម" ដែរ តែមិនបានកំណត់ជាមុនអំពីការសងកាតព្វកិច្ចដោយទ្រព្យសម្បត្តិរួមដែលកើតមានដូចនៅក្នុងរឿងក្ដីខាងលើនេះទេ ដូច្នេះហើយ គេអាចបកស្រាយបានថា ការសងកាតព្វកិច្ចមិនមែនជា "ការចាត់ចែង" ដែលបានចែងក្នុងមាត្រា976 កថា.ទី1នៃក្រមរដ្ឋប្បវេណីកម្ពុជាទេ ហើយការសងកាតព្វកិច្ចនោះនឹងមានសុពលភាព។

### ④ទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ និង ការអនុវត្តដោយបង្ខំ

ប្ដី "A"បានខ្ចីប្រាក់ពីម្ចាស់បំណុល "C" នៅមុនពេលរៀបអាពាហ៍ពិពាហ៍ ហើយមិនទាន់បានសងប្រាក់នោះនៅឡើយ។ Aបានរៀបអាពាហ៍ពិពាហ៍ជាមួយប្រពន្ធ "B" ។ A និង B បានទិញដី និងផ្ទះ ដើម្បីជាការអាស្រ័យនៅ និង បានចុះបញ្ជីជាទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ។ C បានទាមទារឲ្យសងកាតព្វកិច្ចដូចបានលើកឡើងខាងលើ ទៅកាន់ A ប៉ុន្តែ A មិនបានបង់ប្រាក់នោះទេ។ ដូច្នេះហើយ C បានដាក់ពាក្យបណ្ដឹងទាមទារឲ្យ Aសងប្រាក់កម្ចី ហើយ C ក៏ទទួលបាននូវសាលក្រមដែលតុលាការបានទទួលស្គាល់ការទាមទារនោះ ហើយសាលក្រមនោះក៏បានចូលជាស្ថាពរ។ ដោយសារតែ A មិនមានទ្រព្យសម្បត្តិអ្វីជាធំដុំក្រៅពីនេះទេ ដូច្នេះហើយ C បានដាក់ពាក្យសុំអនុវត្តដោយបង្ខំចំពោះអចលនវត្ថុនូវចំណែករបស់Aទៅលើដី និង ផ្ទះខាងលើ។ តើពាក្យសុំនេះនឹងត្រូវបានទទួលស្គាល់ដែរឬទេ? ប្រសិនបើ B ដាក់ពាក្យសុំតវ៉ាណាមួយ តើពាក្យសុំនោះនឹងត្រូវបានទទួលស្គាល់ដែរឬទេ?

គេគិតថា ទោះបីជាពាក្យសុំអនុវត្តដោយបង្ខំរបស់ C មិនត្រូវបានទទួលស្គាល់ក៏ដោយ ក៏Bអាចដាក់ពាក្យបណ្ដឹងតវ៉ារបស់តតិយជន (CCPកម្ពុជា មាត្រា365 កថា.ទី1) បានដែរ ដោយផ្អែកតាមមាត្រា976 កថា.ទី1 និង ទី3 ព្រមទាំងផ្អែកតាមចំណែកលើទ្រព្យសម្បត្តិរួម។

មូលហេតុដែលធ្វើឲ្យគេបានលើកឡើងដូចខាងលើ ព្រោះគេបានគិតថា (1) ផ្អែកលើលក្ខណៈគតិយុត្តនៃការអនុវត្តដោយបង្ខំ ក៏មានគំនិតដែលបានយល់ថា ការអនុវត្តដោយបង្ខំ គឺជាប្រភេទមួយនៃការចាត់ចែងដែលធ្វើឡើងដោយផ្អែកតាមនីតិសាធារណៈ ក៏ប៉ុន្តែការបកស្រាយភាគច្រើនដ៏លើសលប់ គេបានយល់ថា វាគឺជាការលក់ដែលធ្វើឡើងដោយផ្អែកតាមនីតិឯកជនទេ។ (2) នៅក្នុងការបង្កើតសិទ្ធិប្រាតិភោគ ដូចជា ហ៊ីប៉ូតែកជាអាទិ៍ ទើបជា "ការចាត់ចែង" នៃមាត្រា976 កថា.ទី1នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ហើយគួរតែធ្វើការបែងចែងឲ្យដាច់គ្នារវាងករណីនៃការអនុវត្តសិទ្ធិប្រាតិភោគ និង ការអនុវត្តដោយបង្ខំ។

តើនៅពេលធ្វើការអនុវត្តហ៊ីប៉ូតែក ត្រូវការមានការយល់ព្រមរបស់ប្តីប្រពន្ធម្តងទៀតដែរ ឬ យ៉ាងណា?

គេបានបកស្រាយថា ប្រសិនបើប្តីប្រពន្ធបានការបង្កើតសិទ្ធិប្រាតិភោគ ដូចជាហ៊ីប៉ូតែកជាដើម ប្តីប្រពន្ធនោះក៏បានព្យាករណ៍ទុកដែរថា នឹងមានការអនុវត្តនូវសិទ្ធិហ៊ីប៉ូតែកនេះនៅថ្ងៃក្រោយ ដូច្នេះ ការយល់ព្រមដែលបានធ្វើឡើងនៅពេលបង្កើតហ៊ីប៉ូតែក ក៏បានរួមបញ្ចូលទាំងការព្រមព្រៀងសម្រាប់ការអនុវត្តហ៊ីប៉ូតែកនោះផងដែរ។ ជាធម្មតា គេបានគិតថា នៅក្នុងការយល់ព្រមចំពោះការបង្កើតហ៊ីប៉ូតែក ភាគីក៏បានយល់ព្រមសម្រាប់ការអនុវត្តនោះភ្លាមៗផងដែរ ដោយមានបំណងថា នឹងទទួលយកនូវអនុវត្តដែលអាចនឹងកើតឡើង។

## 5 ប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ និង សោហ៊ុយអាពាហ៍ពិពាហ៍ និង ករណីយកិច្ចរួមគ្នារបស់ប្តីប្រពន្ធ

### <u>ការទទួលបន្ទុកសោហ៊ុយអាពាហ៍ពិពាហ៍</u>

ប្តីប្រពន្ធត្រូវមានចំណែកបន្ទុកលើសោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍ ដោយពិចារណាលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និង ស្ថានភាពផ្សេងៗទៀត (CCកម្ពុជា មាត្រា971)។

មាត្រានេះ គឺជាមាត្រាដែលបានចែងអំពីបន្ទុកនៃសោហ៊ុយដែលចាំបាច់ដើម្បីអាចថែទាំជីវភាពរួមនៃអាពាហ៍ពិពាហ៍ ដោយប្តីប្រពន្ធត្រូវទទួលបន្ទុកនេះ ផ្អែកទៅតាមទ្រព្យសម្បត្តិ ប្រាក់ចំណូល ឋានៈក្នុងសង្គម និង មុខរបររបស់ប្តីប្រពន្ធទាំងសងខាងជាអាទិ៍។ គេក៏បាននិយាយថា មាត្រានេះ ក៏ជាការឆ្លុះបញ្ចាំងនូវផ្នែកសេដ្ឋកិច្ចដែលស្តីពីករណីយកិច្ចរួមរស់នឹងគ្នា សហការ និង សង្គ្រោះគ្នាទៅវិញទៅមករបស់ប្តីប្រពន្ធដែលជាការបង្កើតចំណុចសំខាន់នៃអាពាហ៍ពិពាហ៍ផងដែរ។

ខ្លឹមសារលម្អិតនៃសោហ៊ុយអាពាហ៍ពាហ៍រួមមាន៖ សោហ៊ុយសម្រាប់ការស្លៀកពាក់ ម្ហូបអាហារ និង ការស្នាក់នៅ ថ្លៃសម្រាប់សម្រាលកូន ថ្លៃព្យាបាល ថ្លៃសិក្សា ថ្លៃមើលថែទាំកូន និង ថ្លៃសម្រាប់ការកម្សាន្តដែលសមរម្យជាអាទិ៍។

គេបានគិតថា នៅក្នុងថ្លៃសិក្សា ដូចជា ចំណាយសម្រាប់ការសិក្សាថ្នាក់កម្រិតខ្ពស់ដែលរួមមាន ប្រាក់សម្រាប់បង់ថ្លៃចូលរៀន ថ្លៃបង់តាមមុខវិជ្ជា និងសម្ភារៈសិក្សាជាអាទិ៍ក្នុងទំហំដ៏សមរម្យ ក៏បានរាប់បញ្ចូលជាសោហ៊ុយអាពាហ៍ពិពាហ៍ផងដែរ ដោយធ្វើការពិចារណាទៅលើ ទឹកចិត្ត និង សមត្ថភាពក្នុងការសិក្សារបស់កូន ព្រមទាំងស្ថានភាពសេដ្ឋកិច្ច និង លទ្ធភាពនៃធនធានរបស់ឪពុកម្តាយ (សេចក្តីសម្រេចតុលាការគ្រួសារប្រទេសជប៉ុន៖ 大阪家審 1966（昭和 41）・12・13 家月 19 巻 7 号 73 頁、ដីកាសម្រេចរបស់សាលាឧទ្ធរណ៍៖ 広島高決 1975（昭和 50）・7・17 家月 28 巻 10 号 1940 頁、បានបង្គាប់ឲ្យគ្រូពេទ្យដែលត្រូវជាប្តីទទួលបន្ទុកថ្លៃសិក្សាសម្រាប់ការសិក្សាផ្នែកវេជ្ជសាស្ត្រ)។

បន្ថែមពីនេះទៀត ពាក្យថា "កូនដែលមិនទាន់ដឹងក្តី" មានន័យចង្អៀតជាង ពាក្យថា "អនីតិជន" ហើយពាក្យនេះមិនបានរាប់បញ្ចូលនូវអនីតិជនដែលអាចរស់នៅដោយឯករាជ្យទេ។ ប៉ុន្តែ ទោះបីជា បុគ្គលនោះបានក្លាយជានីតិជនហើយក៏ដោយ ប៉ុន្តែ ប្រសិនបើបុគ្គលនោះនៅជានិស្សិត ឬ ត្រូវការការព្យាបាលនៅមន្ទីរពេទ្យ ឬ ការថែរទាំងពីឪពុក

ម្តាយដោយសារតែភាពទន់ខ្សោយ (ជំងឺ) ហើយមិនអាចរស់នៅដោយឯករាជ្យបាន គេនឹងត្រូវរាប់ចូលថាជាកូនដែលមិនទាន់ដឹងក្តី (សាលដីកាសាលាឧទ្ធរណ៍ប្រទេសជប៉ុន៖ 東京高決 1971（昭和 46）・3・15 家月 23 巻 10 号 44 頁参照）។ ម្យ៉ាងវិញទៀត ទោះបីជាបានបញ្ចប់ការសិក្សានៅវិទ្យាល័យក៏ដោយ បើសិនជាក្មេងនោះមិនអាចធ្វើការបានដោយសារតែមានជម្ងឺ "បាត់បង់នូវការទាក់ទងនឹងដំណើរជីវិតប្រចាំថ្ងៃ (ប្រភេទនៃជម្ងឺទាក់ទងនឹងស្មារតី)" (កូនស្រីច្បងដែលមានអាយុ19ឆ្នាំ) ក៏អាចហៅថា ជាក្មេងដែលមិនទាន់ដឹងក្តីដែលត្រូវការនូវអាហារកាតព្វកិច្ចផងដែរ (ដីកាសម្រេចរបស់សាលាឧទ្ធរណ៍៖ 大阪高決 2004（平成 16）・1・14 家月 56 巻 6 号 155 頁））។

ម្យ៉ាងវិញទៀត តាមរយៈការប្រកាសឲ្យប្រើ "តារាងកំណត់អំពីសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន និង សោហ៊ុយអាពាហ៍ពិពាហ៍" (យោង៖ 判タ 1111 号 285 頁以下) នៅក្នុងខែមេសា ឆ្នាំ2003 នៅក្នុងការអនុវត្តជាក់ស្តែង ដើម្បីឲ្យមានភាពងាយស្រួល និង ឆាប់រហ័សក្នុងការមើលឃើញ អំពីទំហំដែលនឹងត្រូវក្លាយជាចំនួនទឹកប្រាក់នៃសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន និង សោហ៊ុយអាពាហ៍ពិពាហ៍ដោយផ្អែកទៅលើចំណូលរបស់គូភាគី គេបានបង្កើតតារាងនេះ ដោយធ្វើការសន្មត និង កំណត់នូវកាតព្វកិច្ចដែលត្រូវបង់ពន្ធ ការចំណាយពិសេស ថ្លៃជីវភាពរបស់គូភាគី យោងតាមបទប្បញ្ញត្តិពាក់ព័ន្ធ និង ឯកសារស្ថិតិ ហើយតារាងនេះត្រូវបានគេយកមកប្រើប្រាស់ជាញឹកញាប់។

ប៉ុន្តែ យ៉ាងណាក៏ដោយ ចំពោះតារាងគណនាបែបសាមញ្ញខាងលើនេះ ភាគច្រើនមានការរិះគន់ថា បានដកនូវថ្លៃចំណាយរបស់ភាគីអស់ចំនួន 60% ជាដើម ដូច្នេះ សូម្បីតែថ្លៃជីវភាពអប្បបរមារបស់កុមារក៏មិនអាចធានាបានដែរ និង វាមានភាពខុសគ្នាទៅនឹងស្ថានភាពនៃការកើនឡើងនូវគម្លាតគុណភាពទំនិញ និងភាពក្រីក្រជាក់ស្តែងជាដើម ព្រមទាំងមិនអាចឆ្លើយតបចំពោះថ្លៃសិក្សានៅមជ្ឈមណ្ឌលឯកជនដែលថែទាំកុមារ និង ថ្លៃសិក្សានៅសាលារៀន ម៉្យាងទៀត វាមានគម្លាតឆ្ងាយពីគ្នារវាងការចំណាយ និង បន្ទុកនាពេលបច្ចុប្បន្ន។

បន្ទាប់មកនៅខែវិច្ឆិកា ឆ្នាំ២០១៦ Committee on Equality of Men and Women បានបង្កើតនូវសេចក្តីព្រៀងស្តីអំពី វិធីគណនាថ្មី ដែលនឹងអាចបង្កើន1.5ដង នៃតារាងគណនាបែបសាមញ្ញក្នុងពេលបច្ចុប្បន្ននេះ ដោយផ្អែកលើស្ថានភាពនៃតម្រូវការរស់នៅជាក់ស្តែង（យោង៖ 日弁連両性の平等に関する委員会編『養育費・婚姻費用の新算定表マニュアル』2 頁以下（日本加除出版、2017 年）参照）។

## <u>ការទទួលខុសត្រូវដោយសាមគ្គីភាពចំពោះកាតព្វកិច្ច</u>

ក.សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្តីប្រពន្ធ និង សោហ៊ុយដើម្បីការអប់រំ ឬ ការព្យាបាល ថែទាំកូន ជាអាទិ៍ ខ. កាតព្វកិច្ច និង ករណីយកិច្ចផ្សេងទៀត ដែលប្តីប្រពន្ធបានព្រមព្រៀងតាមលិខិតជាលាយល័ក្ខអក្សរក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គ.សោហ៊ុយដើម្បីគ្រប់គ្រង និង រក្សាទ្រព្យសម្បត្តិរួម (CC កម្ពុជា មាត្រា975)។

ហេតុនេះ ក្នុងករណីជាក់ស្តែង តើ「សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្តីប្រពន្ធ」និង「សោហ៊ុយដើម្បីការអប់រំ ឬការព្យាបាល ថែទាំកូន ជាអាទិ៍」មានវិសាលភាពកម្រិតណា ជាចំណុចបញ្ហា។

មាត្រា975នេះ មិនត្រឹមតែជាបញ្ញត្តិដែលកំណត់ថា កម្មជាទទួលយកប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធប៉ុណ្ណោះទេ ថែមទាំងកំណត់ការទទួលបន្ទុកកាតព្វកិច្ចរួមដោយសមស្រប ក្នុងវិសាលភាពសមហេតុផលមួយ ដែលមិនឲ្យប្តី ឬ ប្រពន្ធទទួលបន្ទុកកាតព្វកិច្ចហួសហេតុ ទោះបីជាពិចារណាពីទស្សនៈរបស់តតិយជនក៏ដោយ។ មាត្រា 975 កថាខណ្ឌទី២ ក៏បានពិចារណាដើម្បីជៀសវាងមិនឲ្យមានការទទួលបន្ទុកកាតព្វកិច្ចហួសហេតុ ដោយទាមទារឲ្យមានលក្ខខណ្ឌធ្វើជាលាយលក្ខអក្សរ និង ការព្រមព្រៀងពីប្តីប្រពន្ធទាំងសងខាង។

ប៉ុន្តែ ក្នុងករណីទទួលយកប្រព័ន្ធទ្រព្យសម្បត្តិរួម កាតព្វកិច្ចដែលជារបស់ប្តីប្រពន្ធតែម្ខាង ឬ ទាំងសងខាង ជាគោលការណ៍ គឺជាបន្ទុកនៃទ្រព្យរួម ហេតុនេះ យើងត្រូវកំណត់ថា នេះជាកាតព្វកិច្ចរួមរបស់ប្តីប្រពន្ធទាំងសងខាង (ច្បាប់គ្រួសារ California មាត្រា911)។ ដូចនេះ ទោះបីជាទ្រព្យសកម្មរួមក៏ដោយ ក្រៅពីសកម្មភាពរៀបចំថែរក្សាការពារទ្រព្យរួម និង ការចុះឈ្មោះក្នុងគោលបញ្ជីជាអាទិ៍ ក៏មានករណីដែលសិទ្ធិចំពោះទ្រព្យរួមរបស់សហព័ទ្ធម្ខាងទៀត (សិទ្ធិលើចំណែកដោយឡែក) មិនត្រូវបានរក្សាការពារទេ នៅក្នុងទំនាក់ទំនងជាមួយនឹងតតិយជនសុចរិតនិងគ្មានកំហុស។ ទ្រព្យអកម្មដែលជាកាតព្វកិច្ចក៏ដោយ ក៏ត្រូវពិចារណាដូចគ្នាដែរ ដោយរក្សាសមភាពរវាងការការពារតតិយជន និង ការទទួលបន្ទុកហួសហេតុរបស់ប្តីប្រពន្ធ។

នៅក្នុងក្រមរដ្ឋប្បវេណីបារាំងក៏ដោយ ជាគោលការណ៍ ម្ចាស់បំណុលមិនអាចទាមទារទៅដល់ទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធរបស់កូនបំណុលឡើយ ប៉ុន្តែ ទោះបីជាសហព័ទ្ធតែម្ខាងទទួលនូវកាតព្វកិច្ចក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ក៏ដោយ ប្រសិនបើកាតព្វកិច្ចនោះពាក់ព័ន្ធនឹងផលប្រយោជន៍គ្រួសារ កាតព្វកិច្ចនោះជាបន្ទុករបស់ទ្រព្យសម្បត្តិរួម ហើយប្រសិនបើកាតព្វកិច្ចនោះជាផលប្រយោជន៍ឯកជនរបស់សហព័ទ្ធតែម្ខាងទេ សហព័ទ្ធនោះត្រូវទទួលបន្ទុកតែម្នាក់ឯង។

នៅប្រទេសជប៉ុន មានទ្រឹស្តី2 ដែលមានគំនិតខុសគ្នាចំពោះវិសាលភាពនៃកាតព្វកិច្ចនៃកិច្ចការគ្រួសារប្រចាំថ្ងៃក្នុងក្រមរដ្ឋប្បវេណីជប៉ុនមាត្រា761 ទី1គឺទ្រឹស្តីអត្តនោម័តដែលយកមូលដ្ឋានពិចារណាលើស្ថានភាពសេដ្ឋកិច្ច និងគោលបំណងនៃសកម្មភាពរបស់ប្តីប្រពន្ធម្នាក់ៗ និង ទី2 គឺទ្រឹស្តីសត្យានុម័តដែលពិចារណាលើសត្យានុម័តនៃប្រភេទ និង សារជាតុនៃសកម្មភាព។ ប៉ុន្តែ ទ្រឹស្តីទូទៅនិងយុត្តិសាស្ត្រជប៉ុនបានយកជំហរកណ្តាល ហើយដើម្បីកំណត់ថាសកម្មភាពណាមួយស្ថិតនៅក្នុងវិសាលភាពនៃកាតព្វកិច្ចនៃកិច្ចការគ្រួសារ ឬ មិនមែននោះ គឺមានភាពខុសគ្នាទៅតាមឋានៈសង្គម ការងារ ធនធាន ចំណូល និងទំនៀមទំលាប់សង្គមក្នុងតំបន់របស់ប្តីប្រពន្ធម្នាក់ៗ និងត្រូវសម្រេចដោយផ្អែកលើស្ថានភាពខាងក្នុងជីវភាពរស់នៅរួមរបស់ប្តីប្រពន្ធដែលធ្វើសកម្មភាពគតិយុត្ត និង គោលបំណងផ្សេងៗនៃសកម្មភាព ព្រមទាំងត្រូវពិចារណាជាសត្យានុម័តលើប្រភេទ និងសារជាតុនៃសកម្មភាពគតិយុត្តនោះផងដែរ (សាលដីកាតុលាការកំពូលប្រទេសជប៉ុន 最判 1969(昭和 44)・12・18 民集 23 巻 12 号 2470 頁)។

ឧទាហរណ៍នៃសកម្មភាពគតិយុត្តដែលត្រូវបានរាប់បញ្ចូលក្នុងវិសាលភាពនៃកិច្ចការគ្រួសារប្រចាំថ្ងៃរួមមាន ការទិញរបស់ដែលចាំបាច់សម្រាប់ជីវភាព ការចុះកិច្ចសន្យាផ្គត់ផ្គង់អគ្គិសនី・ហ្គាស・ទឹក ការចុះកិច្ចសន្យាជួលផ្ទះ ថ្លៃចំណាយលើសុខភាពគ្រួសារ ការកំសាន្ត ការអប់រំ・ការចិញ្ចឹមកូនដែលជាអនីតិជនជាអាទិ៍។ ហើយជាគោលការណ៍ការចាត់ចែងទ្រព្យសម្បត្តិដោយឡែកដែលមានតម្លៃថ្លៃដូចជាអចលនវត្ថុជាអាទិ៍ មិនត្រូវបានរាប់បញ្ចូលទេ (សាលដីកាសាលាឧទ្ធរណ៍ប្រទេសជប៉ុន 東京高判 1975(昭和 50)・1・29 金商 465 号 18 頁 សាលដីកាសាលឧទ្ធរណ៍ប្រទេសជប៉ុន 名古屋高判 1983(昭和 58)・8・10 下民集 34 巻 5-8 合併号 606 頁 ជាអាទិ៍)។ ការខ្ចីប្រាក់ដ៏ច្រើន (សាលក្រមសាលាដំបូង 東京地判 1980(昭和 55)・3・10 判時 980 号 83 頁) ការទិញឧបករណ៍ទាញយកទឹកក្តៅតម្លៃ 41ម៉ឺនយ៉េន (門司簡判 1986(昭和 61)・3・28 判タ 612 号 57 頁) ការទិញក្បួយជប៉ុនដោយក្រេឌីតកាត (大阪簡判 1986(昭和 61)・8・26 判タ 626 号 173 頁) កិច្ចសន្យាក្រេឌីតកាតសម្រាប់ឧបករណ៍សិក្សាសរុប 70ម៉ឺនយ៉េន (八女簡判 2000(平成 12)・10・12 判タ 1073 号 192 頁) ការប្រើប្រាស់ប្រាក់ក្រេឌីតកាតចំនួន 431ម៉ឺនយ៉េន (東京地判 2014(平成 26)・2・2626LEX/DB 文献番号 25517740)ត្រូវបានកំណត់ថាមិនសមស្របនឹងសកម្មភាពពាក់ព័ន្ធនឹងកិច្ចការគ្រួសារទេ។

ផ្ទុយពីនេះ ថ្លៃសេវាទូរទស្សន៍ NHK (ប្រព័ន្ធផ្សព្វផ្សាយសាធារណៈ) (札幌高判2010 (平成22)・11・5判時2101号61頁、東京高判2010(平成22)・6・29判時2104号40頁、千葉地判平成2010(平成22)・10・28TKC法律情報データベース【文献番号】25464116) កាតព្វកិច្ចនៃកិច្ចសន្យាបង់ប្រាក់ថ្លៃទិញឧបករណ៍សិក្សាភាសាអង់គ្លេសសម្រាប់កូនក្មេងតម្លៃ 60 ម៉ឺនយ៉េន (東京地判1998(平成10)・12・2判タ1030号257頁) សោហ៊ុយថ្លៃអប់រំកុមារអន្តរជាតិចំនួន 379 ម៉ឺនយ៉េន(●26LEX/DB文献番号25517740)។ ●(東京地判2012(平成24)・5・31LEX/DB文献番号25494410)ហើយ ថ្លៃឈ្នួលពន្យាពេលចំនួន 25 ម៉ឺនយ៉េន (東京地判2013(平成25)・1・22LEX/DB文献番号25510430) ថ្លៃជួសជុលអាគារចំនួន 697 ម៉ឺនយ៉េន (東京地判2014(平成26)・1・30LEX/DB文献番号25517697) ថ្លៃសាលាបង្រៀនយូដូសម្រាប់កូនក្មេងចំនួន 95 ម៉ឺនយ៉េន (横浜地判2016(平成28)・3・31LEX/DB文献番号25544354) ត្រូវបានទទួលស្គាល់ថាជាកាតព្វកិច្ចដោយសាមគ្គីភាពដោយកំណត់ថាក្នុងវិសាលភាពនៃកិច្ចការគ្រួសារប្រចាំថ្ងៃ។

### សាលក្រមសាលាដំបូងភ្នំពេញចុះថ្ងៃទី7 ខែ7 ឆ្នាំ2016

អង្គហេតុ ៖ ប្តីប្រពន្ធស្របច្បាប់ដែលគ្មានវិវាទអំពីការលែងលះដែលបានរស់នៅបែកគ្នា និងការបែកបាក់អាពាហ៍ពិពាហ៍រវាងគ្នា ប៉ុន្តែមានវិវាទអំពីទ្រព្យសម្បត្តិរួម និង កាតព្វកិច្ចរួមរបស់ប្តីប្រពន្ធ។

ប្តីប្រពន្ធបានព្រមព្រៀងអំពីការលែងលះ ប៉ុន្តែមានវិវាទអំពីកាតព្វកិច្ចដ៏ច្រើន និង ដី 2កន្លែង ថាជាទ្រព្យសម្បត្តិរួម ឬ មិនមែន។

តុលាការបានច្រានចោលការទាមទាររបស់ប្តី ដោយផ្អែកលើក្រមរដ្ឋប្បវេណីកម្ពុជាមាត្រា975 ទាក់ទងនឹងបញ្ហានៃទំនួលខុសត្រូវក្នុងការបញ្ជាក់ ដែលមិនអាចពឹងផ្អែកទាំងស្រុងលើការព្រមព្រៀងក្នុងការបញ្ជាក់។

មានន័យថា ប្តីប្រពន្ធបានព្រមព្រៀងអំពីការលែងលះដោយទទួលស្គាល់ការបែកបាក់អាពាហ៍ពិពាហ៍ ប៉ុន្តែពួកគេមានវិវាទអំពីដីដែលជាកម្មសិទ្ធិរបស់ប្តីថាជាទ្រព្យសម្បត្តិដោយឡែក ឬ ទ្រព្យសម្បត្តិរួម និង ប្រាក់បំណុលយ៉ាងច្រើន (កាតព្វកិច្ចជាប្រាក់រហូតដល់ 13ម៉ឺនដុល្លា និង កាតព្វកិច្ចដែលខ្ចីពីក្រុមហ៊ុនចំនួន 5ម៉ឺនដុល្លា) ថាជាកាតព្វកិច្ចរួម ឬ យ៉ាងណា។

យោងតាមក្រមរដ្ឋប្បវេណីមាត្រា975 កថាខណ្ឌទី2 ដែលបញ្ញត្តថា ប្តីប្រពន្ធមានទំនួលខុសត្រូវដោយសាមគ្គីភាពចំពោះ កាតព្វកិច្ចនិងករណីយកិច្ចផ្សេងទៀតដែលប្តីប្រពន្ធទាំងសងខាងបានព្រមព្រៀងតាមលិខិត ឬ កាតព្វកិច្ចនិងករណីយកិច្ចផ្សេងទៀតដែលប្តីប្រពន្ធណាម្ខាងបានទទួលបន្ទុកដោយមានការយល់ព្រមតាមលិខិតជាលាយល័ក្ខអក្សរពីប្តីប្រពន្ធម្ខាងទៀត ហើយយោងតាមអង្គហេតុដែលតុលាការទទួលស្គាល់ និងការស្រាវជ្រាវភស្តុតាង•សាក្សីជាអាទិ៍ តុលាការបានបង្ហាញថា មិនមានការព្រមព្រៀងណាមួយបានធ្វើឡើងអំពីកាតព្វកិច្ចខាងលើនេះទេ ហេតុនេះ តុលាការសម្រេចមិនទទួលស្គាល់ការអះអាងរបស់ភាគីខាងប្តី។

## 6 ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ និង ការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ

### ប្រព័ន្ធបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះ

នៅក្រោមប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ កម្ពុជាក៏បានតាក់តែងបញ្ញត្តិអំពីការបែងចែក និង ការជម្រះទ្រព្យសម្បត្តិប្តីប្រពន្ធនៅពេលលែងលះផងដែរ។ ① ក្នុងករណីលែងលះ ប្តីប្រពន្ធត្រូវបែងចែកទ្រព្យសម្បត្តិដោយយុត្តិធម៌ផ្អែកតាមការពិភាក្សារបស់ភាគីទាំងសងខាង។ ② ក្នុងករណីដែលមិនអាចពិភាក្សាគ្នារវាងប្តីប្រពន្ធបានទេ ត្រូវបែងចែកដោយផ្អែកតាមចំណុចនីមួយៗ ដូចកំណត់ខាងក្រោមនេះ។ (ក) សហព័ទ្ធនីមួយៗ ត្រូវទទួលបន្ទុកនូវទ្រព្យសម្បត្តិដោយឡែកដែលបានកំណត់នៅក្នុងមាត្រា972 (ទ្រព្យសម្បត្តិដោយឡែក)។ (ខ) បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធនីមួយៗ មានសិទ្ធិទទួលយក ១ភាគ២ នៃទ្រព្យរួម។ ប៉ុន្តែ បើមានករណីពិសេស និង មានការទាមទាររបស់ប្តីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗ ដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្តនិងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និង ផលប្រយោជន៍របស់កូន ជាអាទិ៍។ ③ គេហកិច្ច ត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះដែរ (CCកម្ពុជា មាត្រា980)។

ទ្រព្យសម្បត្តិប្តីប្រពន្ធអាចបែងចែកជា ៣ប្រភេទ គឺទ្រព្យសម្បត្តិរួម ទ្រព្យសម្បត្តិដោយឡែករបស់ប្តី និង ទ្រព្យសម្បត្តិដោយឡែករបស់ប្រពន្ធ។ ចំពោះទ្រព្យសម្បត្តិប្តីប្រពន្ធ បើសិនជានៅពេលរំលាយអាពាហ៍ពិពាហ៍ (លែងលះ) ប្តីប្រពន្ធឈានដល់ការព្រមព្រៀងបែងចែកទ្រព្យសម្បត្តិ តាមការពិភាក្សារបស់ប្តីប្រពន្ធ ដោយបង្ហាញឲ្យច្បាស់អំពីទ្រព្យសម្បត្តិរួម ចំណែកនៃទ្រព្យសម្បត្តិដោយឡែក ទំហំ (រួមទាំងពេលធ្វើលទ្ធកម្ម ដើមហេតុនៃការធ្វើលទ្ធកម្ម និង ប្រវត្ត ជាអាទិ៍) តម្លៃ ជាអាទិ៍ ហើយការព្រមព្រៀងនោះត្រូវបានគោរព។

មាត្រា980 បានបញ្ញត្តថា នៅពេលដែលមិនអាចធ្វើការពិភាក្សារវាងប្តីប្រពន្ធបាន នោះទ្រព្យសម្បត្តិដោយឡែកត្រូវធ្វើលទ្ធកម្មរៀងៗខ្លួន ហើយទ្រព្យសម្បត្តិរួមជាគោលការណ៍ត្រូវធ្វើលទ្ធកម្មចំណែក 1ភាគ2 ម្នាក់។ មានន័យថា

ដើម្បីធ្វើឲ្យមានភាពស្មើគ្នានៃអាពាហ៍ពិពាហ៍ បញ្ញត្តិច្បាប់បានយកចំណែក1ភាគ2ជាគោលការណ៍ ហើយនៅក្នុងមាត្រា980 កថាខណ្ឌទី2 ចំណុចខ វាក្យខណ្ឌទី2 បានផ្តល់លទ្ធភាពឲ្យបែកចែកចំណែក1ភាគ3 ឬ 1ភាគ4 ក៏បានក្នុងករណីដែលអំឡុងពេលអាពាហ៍ពិពាហ៍មានរយៈពេលខ្លីខ្លាំងពេក ឬ មានស្ថានភាពពិសេសដែលបំពានដល់ភាពត្រឹមត្រូវខ្លាំងនៅពេលដែលអនុវត្តតាមគោលការចែកចំណែក1ភាគ2 ដោយសារកម្រិតនៃបរិច្ចាគទាបពេក ជាអាទិ៍។

វិធីបែងចែលលំអិតត្រូវអនុវត្តតាមបញ្ញត្តិកម្មសិទ្ធិអវិភាគក្នុងគន្លីសិទ្ធិប្រត្យក្ស ដូចជា បែកចែកវត្ថុដោយផ្ទាល់ ការបែកចែកដោយតម្លៃជាប្រាក់ ការបែកចែកដោយបង់ប្រាក់សម្រួល និងការបែកចែកដោយការបង្កើតសិទ្ធិផលុបភោគ ជាអាទិ៍។

ហើយការវាយតម្លៃការងារគេហកិច្ចក្នុងមាត្រា980 កថាខណ្ឌទី3 បានបង្ហាញយ៉ាងច្បាស់ថា ត្រូវពិចារណា និង ចាត់ទុកថា ការងារគេហកិច្ចរបស់មេផ្ទះ (ការបរិច្ចាគគ្មានតម្លៃសេដ្ឋកិច្ច) ក៏ដោយ ក៏ត្រូវវាយតម្លៃថាជាការបរិច្ចាគសម្រាប់ធ្វើលទ្ធកម្ម ថែរក្សា និង បង្កើនទ្រព្យសម្បត្តិដែរ ហើយមានតម្លៃស្មើគ្នានឹងការបរិច្ចាគជាប្រាក់កាក់នៃតម្លៃសេដ្ឋកិច្ច។

យោងតាមការអនុវត្តជាក់ស្តែងក្នុងតុលាការគ្រួសារប្រទេសជប៉ុន (ករណីលែងលះ) នៅជប៉ុនមានបញ្ញត្តប្រព័ន្ធនៃការបែងចែកទ្រព្យសម្បត្តិ (CCជប៉ុន មាត្រា768) ហើយនៅក្នុងការបែងចែកទ្រព្យសម្បត្តិមានសារជាតុដូចជា ការជម្រះទ្រព្យសម្បត្តិប្តីប្រពន្ធ (កត្តានៃការជម្រះ) អាហារកាតព្វកិច្ចសម្រាប់ទ្រទ្រង់ជីវភាពក្រោយពេលលែងលះ (កត្តាអាហារកាតព្វកិច្ច) និងការទាមទារសំណងជម្ងឺចិត្តបណ្តាលមកពីការលែងលះ (កត្តាទាមទារសំណងការខូចខាត)។

## ពេលជាមូលដ្ឋាននៃការបែកចែកទ្រព្យសម្បត្តិ

នៅពេលវិនិច្ឆ័យអំពីការបែងចែកទ្រព្យសម្បត្តិ ពេលជាមូលដ្ឋាននៃទ្រព្យសម្បត្តិរួមដែលជាកម្មវត្ថុ គឺនៅចំណុចពេលដែលទំនាក់ទំនងសហការគ្នាផ្នែកសេដ្ឋកិច្ចរបស់ប្តីប្រពន្ធបានបញ្ចប់ មានន័យថា នៅពេលដែលរស់នៅបែកគ្នាលើកលែងតែមានស្ថានភាពពិសេស។

ផ្ទុយពីនេះ ក៏អាចមានករណីដែលលំបាកក្នុងការទទួលស្គាល់ពេលជាមូលដ្ឋានដែរ ចំពោះការរស់បែកគ្នានៅក្នុងផ្ទះតែមួយ (ករណីដែលរស់នៅជាមួយគ្នាជាលក្ខណៈទម្រង់ ប៉ុន្តែជាក់ស្តែងមិនមានទំនាក់ទំនងនៃការសហការគ្នាក្នុងនាមជាប្តីប្រពន្ធនោះទេ)។ ប៉ុន្តែ ចំពោះចំណុចពេលដែលបញ្ចប់ទំនាក់ទំនងសហការគ្នាផ្នែកសេដ្ឋកិច្ច ដូចជាពេលដាក់ពាក្យសុំលែងលះដោយសន្ទានកម្ម ជាអាទិ៍ តុលាការត្រូវព្យាយាមបញ្ជាក់យកចំណុចពេលដែលមានការព្រមព្រៀង។

## ការបង្ហាញទ្រព្យសម្បត្តិ

ក្រោយពេលកំណត់ច្បាស់លាស់អំពីពេលជាមូលដ្ឋានហើយ យើងត្រូវបង្ហាញទ្រព្យសម្បត្តិទាំងសងខាងក្នុងពេលជាមូលដ្ឋាននោះ។ ក្នុងករណីដែលភាគីនៅតែរឹងរូសមិនព្រមបង្ហាញទ្រព្យសម្បត្តិ តុលាការអាចធ្វើការសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិតាមការអះអាងរបស់ភាគីម្ខាងទៀតបាន បើសិនជាការអះអាងរបស់ភាគីម្ខាងទៀតនោះមានហេតុផលគ្រប់គ្រាន់ ដោយផ្អែកតាមការទាញហេតុផលទាំងមូល។

ការកំណត់ជាទ្រព្យសម្បត្តិដោយឡែក

ក្នុងករណីដែលមានវិវាទអំពីទ្រព្យសម្បត្តិណាមួយជាទ្រព្យសម្បត្តិរួម ឬ ជាទ្រព្យសម្បត្តិដោយឡែក តុលាការត្រូវបង្គាប់ឲ្យភាគីដែលអះអាងថាជាទ្រព្យសម្បត្តិដោយឡែកធ្វើការអះអាង និង បញ្ជាក់ភស្តុតាងដែលជាមូលដ្ឋាន និង ហេតុផលទាក់ទងនឹងទ្រព្យសម្បត្តិដោយឡែកនោះ។

វិធីវាយតម្លៃទ្រព្យសម្បត្តិ

ពេលជាមូលដ្ឋានដែលសម្រាប់វាយតម្លៃទ្រព្យសម្បត្តិ គឺជាពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។

ដូចនេះ ចំពោះវត្ថុដែលមានការប្រែប្រួលតម្លៃដូចជាអចលនវត្ថុ និង ភាគហ៊ុនជាដើម យើងត្រូវបញ្ជាក់អំពីចំនួនតម្លៃចុងក្រោយបំផុត។ ផ្ទុយមកវិញ ប្រាក់សុទ្ធ ប្រាក់សន្សំក្នុងធនាគារ និង កាតព្វកិច្ចជាដើមដែលមិនមានការប្រែប្រួលខ្លាំងអំពីតម្លៃជាប្រាក់ ចំនួនតម្លៃដែលមាននៅពេលរស់នៅបែកគ្នាគឺជា ចំនួនតម្លៃនៅពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។

●ហេតុនេះ នៅតុលាការគ្រួសារទីក្រុងតូក្យូបានបង្កើតតារាងទំនាក់ទំនងទ្រព្យសម្បត្តិអាពាហ៍ពិពាហ៍ ដើម្បីរៀបចំ និង បែងចែកទ្រព្យសម្បត្តិដែលជាកម្មវត្ថុឲ្យបានលឿន និង មានប្រសិទ្ធិភាព។ ① ដំបូង ជំរុញឲ្យភាគីទាំងសងខាងបង្ហាញទ្រព្យសម្បត្តិឲ្យបានឆាប់រហ័ស។ ② បន្ទាប់មក តម្រូវឲ្យភាគីដែលទាមទារបែកចែកទ្រព្យសម្បត្តិធ្វើតារាងអំពីទ្រព្យសម្បត្តិ និង ដាក់តារាងអំពីទ្រព្យសម្បត្តិនោះភ្ជាប់មកជាមួយនឹងឯកសាត្រៀម។ ③ តម្រូវឲ្យដើមចោទផ្ញើរតារាងអំពីទ្រព្យសម្បត្តិនោះតាមអ៊ីម៉ែល ជាអាទិ៍ ទៅឲ្យចុងចម្លើយ។ ④ ចុងចម្លើយត្រូវសរសេរបន្ថែមលើក្រឡោនអំពីការអះអាងតម្លៃរបស់ដើមចោទ និង ក្រឡោនអំពីឯកសារយោងនៃតារាងទ្រព្យសម្បត្តិដែលបានផ្ញើរមកនោះ និង ដាក់តារាងអំពីទ្រព្យសម្បត្តិនោះភ្ជាប់មកជាមួយនឹងឯកសាត្រៀម។ ⑤ បើសិនជាត្រូវបន្ថែម និង ផ្លាស់ប្តូរការអះអាងអំពីកម្មវត្ថុនៃទ្រព្យសម្បត្តិ ដើមចោទ និង ចុងចម្លើយទាំងសងខាងអាចកែតម្រូវលើតារាងទ្រព្យសម្បត្តិនោះ និងដាក់ភ្ជាប់ជាមួយឯកសារត្រៀម។ ⑥ នៅដំណាក់ការបញ្ចប់ការរៀបចំតារាងទ្រព្យសម្បត្តិ តុលាការនឹងតម្រូវឲ្យភាគីដាក់ព័តមាននោះមកតុលាការ ហើយតុលាការនឹងប្រើប្រាស់ពត៌មាននោះសម្រាប់ផ្សះផ្សារ ឬ ចេញសាលក្រម។

ភាគរយនៃការបែងចែក

ដូចបានលើកឡើងខាងលើ ទ្រព្យសម្បត្តិរួមត្រូវបានសន្មតថាបែងចែកតាមភាគរយស្មើគ្នា ប៉ុន្តែក្នុងករណីចាំបាច់ដែលមានស្ថានភាពពិសេសដូចជា មានគម្លាតខុសគ្នាច្បាស់អំពីកម្រិតបរិច្ចាគដើម្បីបង្កើនទ្រព្យសម្បត្តិរួម ភាពចាំបាច់ដើម្បីស្នាក់នៅ និង ទ្រទ្រង់ជីវភាពរបស់កូននិងសហព័ទ្ធជាដើម តុលាការអាចសម្រេចឲ្យបែងចែកខុសពីភាគរយនៃការបែងចែកខាងលើបាន។

នៅប្រទេសជប៉ុនមានការពិភាក្សាអំពីការកំណត់ទ្រព្យសម្បត្តិណាមួយជាកម្មវត្ថុនៃការបែងចែកដូចខាងក្រោម។

**ប្រាក់ចូលនិវត្តន៍នៅពេលអនាគត**

ប្រាក់ចូលនិវត្តន៍ដែលបានទទួលរួចហើយ គឺជាទ្រព្យសម្បត្តិដែលជាកម្មវត្ថុត្រូវបែកចែក ពីព្រោះវាមានលក្ខណៈដូចថ្លៃឈ្នួលផ្ទះដែលត្រូវបង់ក្រោយការស្នាក់នៅ។ ផ្ទុយពីនេះ ប្រាក់ចូលនិវត្តន៍ដែលអាចនឹងត្រូវទទួលនៅពេលអនាគត មិនមែនជាទ្រព្យសម្បត្តិដែលជាកម្មវត្ថុត្រូវបែកចែកទេ ពីព្រោះ វាមានកត្តាមិនច្បាស់លាស់ដូចជា ប្រាក់ខែត្រូវកាត់បន្ថយ បញ្ឈប់ពីការងារ និង ធនក្ស័យនៃកន្លែងធ្វើការជាដើម ប៉ុន្តែ ប្រាក់ចូលនិវត្តន៍ដែលមានលទ្ធភាពខ្ពស់អាចទទួលបាននៅពេលឆាប់ៗខាងមុខ ភាគច្រើនក៏ជាកម្មវត្ថុសម្រាប់បែងចែកដែរ។

**ប្រាក់ចូលនិវត្តន៍ឯកជននៅពេលអនាគត**

ប្រាក់ចូលនិវត្តសម្រាប់បុគ្គលិកឯកជន និង ប្រាក់ចូលនិវត្តន៍សម្រាប់មន្ត្រីរាជការគឺជាកម្មវត្ថុនៃប្រព័ន្ធបែកចែកប្រាក់ចូលនិវត្តន៍ ហេតុនេះ យើងមិនយកមកពិចារណានៅពេលបែងចែកទ្រព្យសម្បត្តិទេ។ ផ្ទុយមកវិញ ចំពោះប្រាក់ចូលនិវត្តន៍របស់សហគ្រាសគឺមានគោលបំណង និង សារជាតុផ្សេងគ្នាៗជាច្រើន ហេតុនេះ យើងត្រូវដោះស្រាយតាមករណីជាក់ស្តែងនីមួយៗ។

**ការកំណត់កាតព្វកិច្ច**

ចំពោះកាតព្វកិច្ចដែលកើតចេញពីកិច្ចការគ្រួសារប្រចាំថ្ងៃ ត្រូវក្លាយជាការទទួលខុសត្រូវដោយសាមគ្គីភាពរបស់ប្តីប្រពន្ធ (CCជប៉ុន 761) ហេតុនេះ ប្តីប្រពន្ធត្រូវទទួលបន្ទុក ១ភាគ២ ម្នាក់។ ចំពោះសោហ៊ុយអាពាហ៍ពិពាហ៍ដែលមិនទាន់បង់ពីមុន ក៏តុលាការទទួលស្គាល់ឲ្យជម្រះនៅពេលបែងចែកទ្រព្យសម្បត្តិដែរ (សាលក្រមតុលាការកំពូល 最判1978(昭和53)･11･24民集32巻8号1529頁)។

ចំពោះកាតព្វកិច្ចដែលភ្ជាប់ជាមួយនឹងការថែរក្សា និង បង្កើនទ្រព្យសម្បត្តិរួមដូចជា កម្ចីដែលកើតឡើងនៅពេលលទ្ធកម្មអចលវត្ថុដែលជាទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ ត្រូវយកមកពិចារណានៅពេលគណនាជម្រះភាគរយទាំងមូល។

A: ចំនួនសរុបនៃទ្រព្យសម្បត្តិ និង បន្ទុកកាតព្វកិច្ចរបស់ដើមចោទ

B: ចំនួនសរុបនៃទ្រព្យសម្បត្តិ និង បន្ទុកកាតព្វកិច្ចរបស់ចុងចម្លើយ

ចំនួននៃការបែងចែកទ្រព្យសម្បត្តិដោយជម្រះ =(A＋B)÷2－A

**ការកំណត់ទ្រព្យសម្បត្តិដែលមានឈ្មោះតតិយជន**

ចំពោះប្រាក់សន្សំក្នុងគណនីដែលមានឈ្មោះកូនគឺជាទ្រព្យសម្បត្តិរបស់កូន ហើយមិនមែនជាកម្មវត្ថុសម្រាប់បែកចែកទ្រព្យសម្បត្តិដោយជម្រះនោះទេ ប្រសិនបើកូនបានសន្សំពីការធ្វើការក្រៅម៉ោង ឬ បានពីការធ្វើការងារបន្តិចបន្តួច។ ប៉ុន្តែ ករណីប្រាក់សន្សំដែលប្តីប្រពន្ធរៀបចំសម្រាប់ការបន្តការសិក្សារបស់កូននៅពេលអនាគត គឺជាកម្មវត្ថុនៃការបែងចែកទ្រព្យសម្បត្តិ។

ម៉្យាងទៀត ធនធាននៃនីតិបុគ្គល (ក្រុមហ៊ុន) ដែលប្តីប្រពន្ធណាម្ខាងគ្រប់គ្រង ជាគោលការណ៍ត្រូវកំណត់ថាជាទ្រព្យសម្បត្តិដោយឡែករបស់នីតិបុគ្គលដែលមានលក្ខណៈសម្បត្តិនោះ។ ប៉ុន្តែ ក្នុងករណីដែលលក្ខណសម្បត្តិរបស់នីតិបុគ្គលមានតែទម្រង់ខាងក្រៅ និង ឈានដល់ការប្រើប្រាស់ដោយបំពាន មានករណីខ្លះយើងអាចសន្មតថាជាទ្រព្យសម្បត្តិរបស់បុគ្គលដែលគ្រប់គ្រងនោះ។

### ការបែងចែកទ្រព្យសម្បត្តិដោយអាហារកាតព្វកិច្ច

ទោះបីជាគ្មានការបែកចែកទ្រព្យសម្បត្តិដោយជម្រះក៏ដោយ យ៉ាងហោចណាស់យើងគួរទទួលស្គាល់ការផ្តល់អាហារកាតព្វកិច្ចពីសហព័ទ្ធដែលមានជីវភាពធូធារ ចំពោះសហព័ទ្ធដែលមានការលំបាក និង ត្រូវការជំនួយដល់ជីវភាពដែរ។ ចំណុចដែលត្រូវពិចារណាមាន ធនធាន និង ចំណូលរបស់ប្តីប្រពន្ធទាំងសងខាង ការងារ អាយុ ស្ថានភាពសុខភាព ស្ថានអំពីជីវភាពក្រោយពេលលែងលះ លទ្ធភាពដែលអាចធ្វើការងារ និង រៀបអាពាហ៍ពិពាហ៍សារជាថ្មី មានឬគ្មានកូន និងស្ថានភាពនៃការថែរក្សាកូន ការសហការ និង ជំនួយពីគ្រួសារ ជំនួយពីសហគមន៍ និង ប្រាក់សោធននិវត្តន៍ និងស្ថានភាពទាំងអស់។

នៅក្នុងសាលក្រមមុនៗក៏ដោយ ក៏ខុសគ្នាតាមករណីនីមួយៗដោយផ្អែកលើអាយុ ស្ថានភាពសុខភាព និង លទ្ធភាពធ្វើការងារជាដើម តែតុលាការតែងពិចារណារយៈពេលចាប់ពីពេល 2～3ឆ្នាំរហូតដល់ភាគីដែលលែងលះអាចទ្រទ្រង់ជីវភាពខ្លួនឯង ហើយវិធីបង់ប្រាក់ជាគោលការណ៍គឺបង់ផ្តាច់ ប៉ុន្តែក្នុងករណីដែលភាគីម្ខាងទៀតខ្វះធនធានសម្រាប់បង់ ក៏មានឲ្យបង់តាមរយៈពេលកំណត់ណាមួយដែរ។

## 7 សន្និដ្ឋាន

### ការការពារអាពាហ៍ពាហ៍ជាក់ស្តែងនៅកម្ពុជា

នៅពេលតាក់តែងក្រមរដ្ឋប្បវេណីកម្ពុជា យើងបានដឹងអំពីប្តីប្រពន្ធគ្មានចំនងអាពាហ៍ពិពាហ៍ជាក់ស្តែងមានចំនួនច្រើន ដែលបានរស់នៅជីវភាពរួមគ្នា និង មានកូនក្នុងនាមជាប្តីប្រពន្ធតាមការជាក់ស្តែង ដោយមិនបានប្រកាសផ្សាយជាសាធារណនូវអាពាហ៍ពិពាហ៍ និង មិនបានចុះបញ្ជីអាពាហ៍ពិពាហ៍តាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ មាត្រា 12 និង 14 ជាអាទិ៍។ ក្រោយពេលអនុវត្តក្រមរដ្ឋប្បវេណីថ្មីរបស់កម្ពុជាក៏ដោយ ក៏ប្តីប្រពន្ធគ្មានចំនងអាពាហ៍ពិពាហ៍ដែលរស់នៅជីវភាពរួមគ្នា ដោយមិនបានធ្វើតាមនីតិវិធីអាពាហ៍ពិពាហ៍ត្រឹមត្រូវ មានចំនួនមិនតិចនោះទេ។ យើងអាចដោះស្រាយតាមទស្សនអនីតិសង្វាសស្រដៀងអាពាហ៍ពិពាហ៍បាន។ ជាក់ស្តែងមុនការអនុវត្តក្រមរដ្ឋប្បវេណីថ្មី នៅក្នុងសាលក្រមក៏ដោយ ក៏មានទទួលស្គាល់ជាអាពាហ៍ពិពាហ៍ស្របច្បាប់ និងអនុវត្តដូចគ្នាតាមបញ្ញត្តិស្តីពីការលែងលះ ហើយសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិ អ្នកមានសិទ្ធិអំណាចមេបាលើកូន និង សោហ៊ុយចិញ្ចឹមបីបាច់ថែរក្សាជាដើម ចំពោះភាគីដែលបានរៀបចំមង្គលការតាមប្រពៃណី និង បានរស់នៅជីវភាពរួមគ្នាក្នុងនាមជាប្តីប្រពន្ធ ទោះបីជាមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ និង គ្មានលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ក៏ដោយ (សាលដីកាតុលាការកំពូលកម្ពុជា カンボジア最高裁判所民事事件第75号1996年3月14日判決、同第6号1999年1月12日判決)។

ផ្ទុយមកវិញ ក្រោយពេលអនុវត្តអនុក្រឹត្យស្តីពីការការចុះបញ្ជីអាត្រានុកូដ្ឋាន ក៏មានរឿងក្តីកើតឡើងចំពោះករណីមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវ តុលាការមិនទទួលស្គាល់ជាអាពាហ៍ពិពាហ៍ស្របច្បាប់ និង មិនសម្រេចឲ្យលែងលះ ប៉ុន្តែ បានសម្រេចអំពីអ្នកមានអំណាចមេបាលើកូន និង ការបែងចែកទ្រព្យសម្បត្តិ ដើម្បីដោះស្រាយបញ្ហាដោយសារពួកគេមានកូន និងទ្រព្យសម្បត្តិរួម (សាលដីកាតុលាការកំពូលកម្ពុជា カンボジア最高裁判所民事事件第23号2003年1月29日判決)។

សាលក្រមថ្មីៗនេះ ក៏មានចំពោះករណីដែលមិនទទួលស្គាល់អាពាហ៍ពិពាហ៍ស្របច្បាប់ដោយសារមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវ ប៉ុន្តែទទួលស្គាល់អំពីទំនាក់ទំនងអនីតិសង្វាស និងសម្រេចអំពីអំណាចមេបា និងការបែងចែកទ្រព្យសម្បត្តិ (សាលក្រមសាលាដំបូង 2015年1月15日プノンペン始審裁判所民事事件判決第41号、2015年5月5日プノンペン始審裁判所民事事件判決第558号)។

## ថ្លៃអាហារកាតព្វកិច្ចពេលលែងលះ (Alimony)

តាំងពីមុនមកមានការទទួលស្គាល់ការបង់ថ្លៃអាហារកាតព្វកិច្ចនៅពេលលែងលែះ ក្រោមលក្ខខណ្ឌកំណត់មួយចំពោះសហព័ទ្ធដែលមានភាពលំបាកសម្រាប់ជីវភាពក្រោយលែងលះ។ នៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ ឆ្នាំ1989 ក្នុងករណីដែលភាគីមិនមានកំហុសដែលនាំឲ្យមានការលំបាក នៅពេលលែងលះប្តីប្រពន្ធណាម្ខាងត្រូវជួយសង្គ្រោះភាគីម្ខាងទៀតដែលមានភាពលំបាកទៅតាមលទ្ធភាព ហើយភាគីម្ខាងទៀតអាចទាមទារថ្លៃអាហារកាតព្វកិច្ចបាន។ ចំនួននៃតម្លៃអាហារកាតព្វកិច្ចត្រូវកំណត់ដោយគោរពតាមការព្រមព្រៀងរបស់ភាគីទាំងសងខាង ប៉ុន្តែបើមិនអាចព្រមព្រៀងបានទេ តុលាការត្រូវសម្រេច។ ក្នុងករណីរៀបអាពាហ៍ពិពាហ៍ថ្មី ថ្លៃអាហារកាតព្វកិច្ចមិនអាចទទួលបានទៀតទេ (ច្បាប់ដដែល មាត្រា76)។

តុលាការអាចបន្ថែម ឬ បន្ថយថ្លៃអាហាកាតព្វកិច្ចពេលលែងលះបាន តាមពាក្យសុំរបស់ភាគី។ ថ្លៃអាហាកាតព្វកិច្ចអាចកើនឡើង ឬ ថយចុះ អាស្រ័យលើលទ្ធភាពបង់ថ្លៃអាហាកាតព្វកិច្ចពេលលែងលះ និង ភាពចាំបាច់ថ្លៃអាហាកាតព្វកិច្ចពេលលែងលះ។ ថ្លៃអាហាកាតព្វកិច្ចអាចបង់ជាប្រាក់ក៏បាន ឬផ្តល់ជាទ្រព្យសម្បត្តិក៏បាន (ច្បាប់ដដែល មាត្រា77)។ ការមិនបង់ថ្លៃអាហាកាតព្វកិច្ចពេលលែងលះត្រូវមានបទល្មើសព្រហ្មទណ្ឌ ប្រសិនបើមានភស្តុតាងជាក់ស្តែងថាធ្វេសប្រហេសក្នុងការអនុវត្តករណីយកិច្ចដោយគ្មានហេតុផលសមរម្យ (ច្បាប់ដដែល មាត្រា78)។

ជាពិសេស បញ្ញត្តិអំពីថ្លៃអាហាកាតព្វកិច្ចពេលលែងលះក្នុងមាត្រា76 និង 77 នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារមិនមានក្នុងបញ្ញត្តិនៃក្រមរដ្ឋប្បវេណីថ្មីទេ ហើយនេះជាបញ្ញត្តិដែលមានសារៈសំខាន់សម្រាប់ការពារសហព័ទ្ធដែលមានជីវភាពលំបាក ជាមួយនឹងការបែកចែកទ្រព្យសម្បត្តិនៅពេលលែងលះ។ ដូចនេះ យើងបានបកស្រាយឲ្យមាត្រា76 និង 77 នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារនៅតែបន្តមានអានុភាព ដើម្បីបានបំពេញមុខងារដូចបញ្ញត្តិអំពីអាហារកាតព្វកិច្ចពេលបែកចែកទ្រព្យសម្បត្តិក្នុងក្រមរដ្ឋប្បវេណីជប៉ុនមាត្រា768 និង ការផ្តល់តាវកាលិកជាសំណងក្នុងច្បាប់បារាំង។

### សាលក្រមសាលាដំបូងភ្នំពេញ ចុះថ្ងៃទី២៤ ខែ១១ ឆ្នាំ២០១៧

ប្តីប្រពន្ធបានរៀបការក្នុងឆ្នាំ2001 ហើយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវនៅខែ10 ឆ្នាំ2006 ហើយនៅចន្លោះឆ្នាំ2002 ពួកគេមានកូនស្រីច្បង ឆ្នាំ2004មានកូនស្រីបន្ទាប់ និង ឆ្នាំ2006 មានកូនប្រុសពៅ។ រឿងក្តីដែលទាមទារ លែងលះ សោហ៊ុយចិញ្ចឹមបីបាច់ និងបែកចែកទ្រព្យសម្បត្តិរួម ហើយទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធរួម

មាន ដីដែលមានប័ណ្ណកម្មសិទ្ធិបញ្ជាក់ម្ចាស់អចលនវត្ថុចុះ ខែ9 ឆ្នាំ2015 តូប4ជាប់គ្នាលក់ទំនិញក្នុងផ្សារ និង រថយន្ត1 គ្រឿង។

ភាគីទាំងសងខាងបានព្រមព្រៀងគ្នា ហើយផ្អែកតាមព្រមព្រៀងនេះ តុលាការសម្រេចអំពីសោហ៊ុយសិក្សាម្នាក់ ៥០% ហើយប្តីត្រូវបង់ 1លានរៀល រៀងរាល់ខែ ហើយដីដែលមានប័ណ្ណកម្មសិទ្ធិបញ្ជាក់ម្ចាស់អចលនវត្ថុត្រូវធ្វើលទ្ធកម្មឲ្យកូន 3នាក់ ហើយតូប4ជាប់គ្នាត្រូវបែកចែកជា5 ប្រគល់ឲ្យ ដើមចោទ ចុងចម្លើយ និង កូន 3នាក់ (សាលក្រមសាលាដំបូង 2017年11月24日プノンペン始審裁判所民事事件判決第2563号)។

សរុបមក ខ្ញុំបានបកស្រាយអំពីសញ្ញាណនៃក្រមរដ្ឋប្បវេណីថ្មី រឿងក្តីជាក់ស្តែងអំពីការបកស្រាយនិងការអនុវត្តជាដើម ដោយផ្អែកជាចំបងតាមការអនុវត្ត និង ទ្រឹស្តីរបស់ច្បាប់ជប៉ុន នៅក្នុងទំនាក់ទំនងនៃប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធនេះ។ ខ្ញុំយល់ថា ទន្ទឹមនឹងការអភិវឌ្ឍន៍សង្គមនិងសេដ្ឋកិច្ចរបស់កម្ពុជា ការប្រែប្រួលក្នុងគ្រួសារក៏មានឥទ្ធិពលខ្លាំង ហើយការវិសោធនកម្មក្រមរដ្ឋប្បវេណីជាដើម កាន់តែមានភាពចាំបាច់។

## ឯកសារយោង


棚村政行ほか 『家族法実務講義』87～102頁（有斐閣、2012年）

棚村政行 「離婚の際の財産分与と債務の取り扱い」『家事事件の理論と実務』156～181頁（勁草書房、2016年）

新田和憲 「財産分与の調停・審判事件野実務」法曹時報66巻7号27～70頁（2014年）

神野泰一 「人事訴訟事件の審理」法曹時報67巻3号1～39頁（2015年）

松谷佳樹 「婚姻費用・養育費の調停・審判事件の実務」法曹時報66巻6号41～67頁（2014年）

日弁連両性の平等に関する委員会編 『養育費・婚姻費用の新算定表マニュアル』2頁以下（日本加除出版、2017年）

犬伏由子ほか 「家族法改正一婚姻法」戸籍時報751号2頁以下（2017年）

棚村政行ほか 「家族法改正一離婚法」戸籍時報751号20頁以下（2017年） 等